សាកលវិទ្យាល័យ COPENHAGEN

# របាយការណ៍ឃ្លាំមើលព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរការ និង ព្រៃសហគមន៍រុក្ខាវ័ន

## របាយការណ៍ឃ្លាំមើល លើកទី ៤

Argyriou, Dimitris ; Theilade, Ida

កាលបរិច្ឆេទបោះពុម្ពផ្សព្វផ្សាយ៖

២០២៤

កំណែឯកសារ៖

បោះពុម្ពផ្សាយ ជាឯកសារPDF ដែលត្រូវបានដឹងផងដែរថា ជាកំណែនៃកំណត់ត្រា

អាជ្ញាប័ណ្ណឯកសារ៖

CC BY-NC-ND

ការដកស្រង់សម្រាប់កំណែដែលបានបោះពុម្ពផ្សាយ (APA)៖

Argyriou, D., & Theilade, I. (2024)។ របាយការណ៍ឃ្លាំមើលព្រៃឈើ នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរការ និងព្រៃសហគមន៍រុក្ខាវ័ន។ របាយការណ៍ឃ្លាំមើលលើកទី ៤។ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងយុត្តិធម៌បរិស្ថានសម្រាប់ទាំងអស់គ្នា (CEEJA) ។

របាយការណ៍ឃ្លាំមើលលើកទី២

# ការឃ្លាំមើលព្រៃឈើ នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរកា និងសង្ឃរុក្ខាវ៉ន

Dimitris Argyriou, Ida Theilade



» កម្ពុជាបានបាត់បង់គម្របព្រៃឈើជាង ១២ម៉ឺនហិកតា នៅក្នុងឆ្នាំ២០២៣

» ផ្លូវថ្មីៗសម្រាប់ការកាប់ឈើខុសច្បាប់ ភ្ជាប់ពីក្រុមហ៊ុនសម្បទាន ស៊ីងបាយអូថេក (Think Biotech) ចូលទៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ របស់កម្ពុជា

» ការពង្រីកការជីកយករ៉ែ បានកំពុងគំរាមកំហែង ដល់ដែនជម្រកសត្វព្រៃរបស់កម្ពុជា

» ការបែកខ្ញែក និងបាត់បង់ទីជម្រក បានកំពុងគំរាមកំហែងដល់ជីវចម្រុះ នៅក្នុងដែនជម្រកសត្វព្រៃរបស់កម្ពុជា

Funded by
the European Union



# » មាតិកា

» សេចក្តីផ្តើម

» ការបាត់បង់ព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃ
- ព្រៃឡង់
- ព្រៃព្រះរកា
- សង្ឃរុក្ខាវ័ន

» បញ្ហាប្រឈមនៅមូលដ្ឋាន

» ការឃ្លាំមើលរបស់សហគមន៍
- បណ្តាញសហគមន៍ព្រៃឡង់ PLCN
- បណ្តាញសហគមន៍ព្រៃព្រះរកា PFCN
- បណ្តាញសហគមន៍សង្ឃរុក្ខាវ័ន MCF

» ជីវចម្រុះ និងធនធានផ្សេងៗ
- សេចក្តីរាយការណ៍ភាគច្រើនក្រោម អនុផលព្រៃឈើអាចបរិភោគបាន
- សេចក្តីរាយការណ៍ភាគច្រើនក្រោម អនុផលព្រៃឈើដែលប្រើប្រាស់សម្រាប់សិប្បកម្ម
- សេចក្តីរាយការណ៍ភាគច្រើនក្រោម អនុផលព្រៃឈើដែលប្រើជាឱសថ
- សេចក្តីរាយការណ៍ភាគច្រើនក្រោម ដើមឈើប្រភេទឈើប្រណិត
- សេចក្តីរាយការណ៍ភាគច្រើនក្រោម ប្រភេទសត្វព្រៃ

» ការផ្សារភ្ជាប់ការរកឃើញនៅមូលដ្ឋាន ទៅនឹងក្របខ័ណ្ឌជីវចម្រុះសកល
- ការឃ្លាំមើលសកម្មភាពល្មើសច្បាប់ផ្សេងៗ របស់សហគមន៍
- ការឃ្លាំមើលជីវចម្រុះ
- ផែនការសម្រាប់អនាគត

» សេចក្តីថ្លែងការណ៍ពីសហគមន៍

# » សេចក្ដីផ្ដើម



**120,829**
គម្របព្រៃឈើដែលបាន បាត់បង់

**1.4%**
តំបន់គម្របព្រៃឈើ សរុប

**16%**
កំណើនការបាត់បង់ គម្របព្រៃឈើ

កម្ពុជាបានបាត់បង់គម្របព្រៃឈើចំនួន ១២០,៨២៩ ហិកតា នៅក្នុងឆ្នាំ២០២៣ ដែលស្មើនឹង១.៤% នៃតំបន់គម្របព្រៃឈើសរុប។ ការបាត់បង់គម្របព្រៃឈើបានកំណត់គោលដៅលើព្រៃល្អបំផុតរបស់ព្រះរាជាណាចក្រកម្ពុជា។ ជារួម ៤០% នៃការបាត់បង់គម្របព្រៃឈើសរុប ស្មើនឹងចំនួន ៤៨,៧៤៧ ហិកតា បានកើតឡើងនៅក្នុងតំបន់ការពាររបស់ប្រទេសនេះ (តារាងទី១)។
ការបាត់បង់គម្របព្រៃឈើបានកើនឡើងចំនួន ១៦% បើធៀបទៅនឹងឆ្នាំ២០២៣ ដែលជាភាគរយមួយ បានឆ្លុះបញ្ចាំងនៅក្នុងតំបន់ការពារ និងដែនជម្រកសត្វព្រៃផ្សេងៗគ្នា នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ចន្លោះឆ្នាំ២០០១ ដល់ឆ្នាំ២០២៣ កម្ពុជាបាត់បង់គម្របព្រៃឈើចំនួន ២.៨៣ លានហិកតា ស្មើនឹងការថយចុះចំនួន ៣២% នៃគម្របព្រៃឈើចាប់តាំងពីឆ្នាំ២០០០មក។ នេះគឺស្មើនឹងប្រមាណ ១.៦៥ ជីហ្គាតោន (Gt) នៃសមមូលកាបូនឌីអុកស៊ីត (CO2e) ហើយបានរួមចំណែកយ៉ាងច្រើនដល់ការបំភាយឧស្ម័នផ្ទះកញ្ចក់សរុបរបស់ប្រទេស។

## CEEJA ប្រើប្រាស់វិធីសាស្ត្រឃ្លាំមើលដោយសហគមន៍នៅកម្រិតមូលដ្ឋាន រួមបញ្ចូលជាមួយនឹងការឃ្លាំមើលពីចម្ងាយ៖

- ការឃ្លាំមើលនៅកម្រិតមូលដ្ឋាន និងសហគមន៍ដែលប្រមូល ទិន្នន័យតាមរយៈការប្រើប្រាស់ កម្មវិធីទូរស័ព្ទស្មាតហ្វូន និង ការប្រើប្រាស់ឧបករណ៍ដ្រូន។
- វិធីសាស្ត្រឃ្លាំមើល ដោយប្រព័ន្ធបច្ចេកវិទ្យា ផ្កាយរណប ទំនើប៖ ប្រព័ន្ធផ្ដល់សញ្ញា GLAD (សាកលវិទ្យាល័យ Maryland) ឧបករណ៍ FCDM (មជ្ឈមណ្ឌលស្រាវជ្រាវរួម នៃគណៈកម្មាការអឺរ៉ុប) និងការវិភាគលើបណ្ដុំរូបភាពតាមពេល វេលាដែលមានគុណភាពកម្រិតខ្ពស់ នៃតំបន់ត្រូពិចរបស់ពិភពលោក (Planet Labs-Norway International Climate and Forests Initiative)។

[១] ការបាត់បង់គម្របព្រៃឈើក្នុងតំបន់ការពាររបស់ប្រទេសកម្ពុជា ពីឆ្នាំ២០០១ ដល់២០២៣។ មានការគណនាទិន្នន័យពីតំបន់ការពារចំនួនប្រាំមួយប្រភេទផ្សេងគ្នានៅក្នុងប្រទេសកម្ពុជា (ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់បេតិកភណ្ឌធម្មជាតិ និងតំបន់រ៉ាមសារ)។ ប្រភព៖ Hansen/UMD/Google/USGS/NASA

[២] សម្រាប់ពត៌មានបន្ថែមស្ដីពីដែនជម្រកសត្វព្រៃ និងសហគមន៍ សូមមើលនៅក្នុង ២nd CEEJA Monitoring Report

[៣] M. C. Hansen et al, High-Resolution Global Maps of ២១st-Century Forest Cover Change. Science ៣៤២,៨៥០-៨៥៣(២០១៣). DOI:១០.១១២៦/science.១២៤៤៦៩៣

[៤] Forest Canopy Disturbance Monitoring (FCDM) - A freely available tool to assess potential forest degradation

| តំបន់ការពារ | ការបាត់បង់គម្របព្រៃឈើ ឆ្នាំ២០២៣ (ហិកតា) |
|---|---|
| កម្ពុជា | ១២០,៨២៩ |
| ដែនជម្រកសត្វព្រៃ ព្រៃឡង់ | ៩,៥៣២ |
| ដែនជម្រកសត្វព្រៃ បឹងពែរ | ៦,៦៤៨ |
| ដែនជម្រកសត្វព្រៃ ភ្នំសំកុស | ៥,៤៨៦ |
| ដែនជម្រកសត្វព្រៃ គូលែនព្រហ្មទេព | ៤,៧៩៨ |
| ឧទ្យានជាតិបុទុមសាគរ | ៣,៩៨៤ |
| ដែនជម្រកសត្វព្រៃ កែវសីមា | ២,៨៦៩ |
| ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល | ១,៨២៦ |
| ឧទ្យានជាតិ ព្រះមុនីវង្ស | ១,៦៤៧ |
| ដែនជម្រកសត្វព្រៃ ឱរ៉ាល់ | ១,៦១០ |
| ដែនជម្រកសត្វព្រៃ ឆែប | ១,៤២៤ |
| ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង | ១,៤១៣ |
| តំបន់ប្រើប្រាស់ច្រើនយ៉ាង សំឡូត | ៦២៤ |
| ដែនជម្រកសត្វព្រៃលំផាត់ | ៦០៩ |
| ដែនជម្រកសត្វព្រៃ តាតៃ | ៥៩០ |
| ដែនជម្រកសត្វព្រៃ ព្រះរកា | ៥៧៧ |
| ឧទ្យានជាតិ អូរយ៉ាដាវ | ៥៥៨ |
| ដែនជម្រកសត្វព្រៃ ស្រែពក | ៥១០ |
| ដែនជម្រកសត្វព្រៃ ស្នួល | ៤៧៦ |
| ដែនជម្រកសត្វព្រៃ ភ្នំណាមលៀរ | ៤២៩ |
| ដែនជម្រកសត្វព្រៃ ភ្នំត្នោត-ភ្នំពក | ៤០០ |
| តំបន់ប្រើប្រាស់ច្រើនយ៉ាង ដងពែង | ៣៤៥ |
| ដែនជម្រកសត្វព្រៃ សំបូរ | ៣៤៣ |
| តំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ | ២៨៤ |
| ឧទ្យានជាតិ រាម | ២២៩ |
| ដែនជម្រកសត្វព្រៃ ភ្នំព្រេច | ១៨៧ |
| ឧទ្យានជាតិ កោះរ៉ុង | ១៦៩ |
| ដែនជម្រកសត្វព្រៃ សៀមប៉ាង | ១៣៦ |
| ឧទ្យានជាតិវីរៈជ័យ | ១១៦ |
| ដែនជម្រកសត្វព្រៃ ពាមក្រសោប | ៩៦ |
| កោះកាពិ និងកោះដែលពាក់ព័ន្ធ | ៩៤ |
| ឧទ្យានជាតិ ភ្នំគូលែន | ៨៧ |
| ឧទ្យានជាតិ វឿនសៃ-សៀមប៉ាង | ៨៤ |

| តំបន់ការពារ | ការបាត់បង់គម្របព្រៃឈើ ឆ្នាំ២០២៣ (ហិកតា) |
|---|---|
| ដែនជម្រកសត្វផ្សោត កោះសន្ទុក កោះកូនសត្វ និងត្បូងខ្លា | ៨០ |
| ដែនជម្រកសត្វព្រៃរនាមដូនសំ១ | ៧២ |
| ដែនជម្រកសត្វព្រៃ ព្រែកប្រសព្វ | ៧០ |
| តំបន់រ៉ាមសារស្ទឹងត្រែង | ៦៣ |
| ដែនជម្រកសត្វព្រៃសង្ឃរុក្ខាវ័ន | ៥០ |
| ឧទ្យានជាតិព្រះសុរាម្រិតកុសុមៈគីរីរម្យ | ៤៤ |
| តំបន់ការពារទេសភាពន្ទាយឆ្មារ | ៤៣ |
| តំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ | ៣០ |
| តំបន់ការពារទេសភាពទំនាបខាងជើងទន្លេរសាប | ២៧ |
| តំបន់បម្រុងទុកជីវមណ្ឌលបឹងទន្លេសាប | ២៥ |
| តំបន់ប្រើប្រាស់ច្រើនយ៉ាងភ្នំនាងកង្រី ភ្នំទូកមាស | ១៣ |
| ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែនឫស្សីត្រឹប | ៨ |
| តំបន់បេតិកភណ្ឌធម្មជាតិ គីរីរង់ | ៦ |
| តំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្តម្ភសត្វតោ | ៦ |
| តំបន់បេតិកភណ្ឌធម្មជាតិភ្នំត្បែង | ៥ |
| រមណីយដ្ឋានវប្បធម៌ប្រាសាទសំបូរព្រៃគុក | ៥ |
| ឧទ្យានជាតិ កែប | ៤ |
| តំបន់ការពារទេសភាពអាងត្រពាំងថ្ម | ៣ |
| ដែនជម្រកសត្វផ្សោត ខ្សាច់ម្កាក់ និងកោះផ្តៅ | ៣ |
| ដែនជម្រកសត្វព្រៃរនាមដូនសំ២ | ២ |
| តំបន់ការពារទេសភាពអង្គរ  តំបន់ការពារប្រាសាទបេងមាលា | ២ |
| តំបន់ការពារប្រាសាទបេងមាលា | ២ |
| តំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងកាដេរ,បឹងជីឡេង | ១ |
| តំបន់រ៉ាមសារបឹងទន្លេឆ្មា ប្រព័ន្ធទន្លេរង និងតំបន់លិចទឹក | ១ |
| តំបន់ការពារទេសភាព ប្រាសាទព្រះខ័ន | ១ |
| តំបន់ការពារទេសភាព ភ្នំក្រាំងដីមាស | ០ |
| តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំយាយសំ | ០ |
| តំបន់ការពារធម្មជាតិ បឹងស្រូ (Boeung Srou) | ០ |
| តំបន់ការពារទេសភាព ប្រាសាទព្រះវិហារ | ០ |
| សរុប | ៤៨,៧៤៧ |

ការបាត់បង់គម្របព្រៃឈើ នៅក្នុងតំបន់ការពារ របស់ប្រទេសកម្ពុជា ក្នុងឆ្នាំ២០២៣

ក្នុងភាពជាដៃគូជាមួយស្ថាប័នឃ្លាំមើលព្រៃឈើសាកល (GFW) មន្ទីរពិសោធន៍ Global Land Analysis and Discovery (GLAD) នៅសាកលវិទ្យាល័យ Maryland ដោយផ្តល់ទិន្នន័យការបាត់បង់គម្របព្រៃឈើជាសាកលប្រចាំឆ្នាំ ដែលប្រើប្រាស់បណ្តុំផ្កាយរណបចាប់សញ្ញារូបភាពជាស៊េរីពេលវេលារបស់ផ្ទៃផែនដី។ សំណុំទិន្នន័យ របស់ Global Forest Change (GFC) ផ្តល់ទិន្នន័យអំពីការបាត់បង់គម្របដើមឈើទូទាំងពិភពលោក។

ឧបករណ៍តាមដានការរំខានគម្របព្រៃឈើ (FCDM) ដែលបានបង្កើតឡើងនៅមជ្ឈមណ្ឌលស្រាវជ្រាវរួម (JRC) ដែលគាំទ្រដោយគណៈកម្មាការអឺរ៉ុប រកឃើញការរំខាននៃគម្របព្រៃឈើ ពីការចាប់សញ្ញាពីចម្ងាយដោយផ្កាយរណប ហើយអាចផ្តល់នូវការចង្អុលបង្ហាញអំពីដំណើរការបំផ្លាញព្រៃឈើ។ ទោះបីជាយ៉ាងណាក៏ដោយ បើប្រៀបធៀបទៅនឹងការកាប់បំផ្លាញព្រៃឈើការធ្វើផែនទីអំពី 'ការរិចរិលព្រៃឈើ' បានបង្ហាញឱ្យឃើញពីលក្ខណៈបច្ចេកទេសដែលកាន់តែពិបាក ហើយសញ្ញានៃការរំខានដល់គម្របព្រៃឈើ គឺមិនសូវលេចធ្លោនោះទេ ដោយសារវាមិនបណ្តាលឱ្យមានការផ្លាស់ប្តូរគម្របដីឡើយ។

សំណុំទិន្នន័យដែលទទួលបានពីឧបករណ៍ FCDM ត្រូវបានប្រើដើម្បីបំពេញសំណុំទិន្នន័យ GFC នៅពេលវាយតម្លៃការបាត់បង់ព្រៃឈើសរុប នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរកា និងសង្ឃរុក្ខាវ័នរបស់កម្ពុជា។

ប្រភពទិន្នន័យចំនួនពីរត្រូវបានដាក់បញ្ចូលគ្នា និងមើលឃើញនៅក្នុងប្រព័ន្ធសង្កេតព្រៃឈើរួម (IFOROS)៖ ជាវេទិកាអនឡាញដែលអាចត្រូវបានប្រើជាឧបករណ៍អន្តរកម្មមួយ ដើម្បីមើលឃើញប្រភេទព័ត៌មានផ្សេងៗគ្នា សម្រាប់តំបន់ការពាររបស់កម្ពុជា។ វេទិកាជាភាសាអង់គ្លេសអាចចូលប្រើប្រាស់តាមរយៈ https://iforos.live/platform និងជាភាសាខ្មែរអាចចូលប្រើតាមរយៈ https://iforos.live/khmer ហើយតំណភ្ជាប់ទាំងពីរនេះត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ជាមួយនឹងសំណុំទិន្នន័យចុងក្រោយបំផុត ស្តីពីការបាត់បង់គម្របព្រៃឈើ និងទិន្នន័យរបស់សហគមន៍។

# ការបាត់បង់ព្រៃឈើ នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរកា និង សង្ឃរុក្ខាវ័ន

## ដែនជម្រកសត្វព្រៃ ព្រៃឡង់

ដែនជម្រកសត្វព្រៃ ព្រៃឡង់ បានបាត់បង់គម្របព្រៃឈើជាង ៩,៥៣២ ហិកតា នៅក្នុងឆ្នាំ២០២៣។ ចំនួននេះបង្ហាញឱ្យឃើញពីការកើនឡើងចំនួន ១០.៣% បើធៀបនឹងឆ្នាំ២០២២ ដែលរួមចំណែកដល់ការកាត់បន្ថយគម្របព្រៃឈើរបស់ដែនជម្រកសរុបចំនួន ២.៣%។ ជាលទ្ធផលកាបូនឌីអុកស៊ីតចំនួនស្មើនឹង ៥.៨៣ លានតោនត្រូវបានបញ្ចេញទៅក្នុងបរិយាកាស។ ចាប់តាំងពីឆ្នាំ២០០១មក ដែនជម្រកសត្វព្រៃ ព្រៃឡង់បានបាត់បង់គម្របព្រៃឈើចំនួន ៨៥,៨៦៤ ហិកតា ដែលស្មើនឹង ២១% នៃផ្ទៃដីសរុប ហើយបណ្តាលឱ្យមានការបំភាយឧស្ម័នផ្ទះកញ្ចក់ចំនួន ៥២.៩ លានតោន (រូបភាពទី១)។ ព្រៃឡង់ត្រូវបានប្រកាសផ្លូវការជាដែនជម្រកសត្វព្រៃ ដែលមានផ្ទៃដីទំហំ ៤៣១,៦៨៣ ហិកតាដោយក្រសួងបរិស្ថានក្នុងឆ្នាំ២០១៦។ ចំនុចគួរឲ្យព្រួយបារម្ភ គឺច្រើនជាងពាក់កណ្តាល នៃការកាប់បំផ្លាញព្រៃឈើសរុបចំនួន ៥៣% និងការបំភាយឧស្ម័នពាក់ព័ន្ធបានកើតឡើងចាប់តាំងពីឆ្នាំ២០១៨។

លើសពីនេះទៀត ឧបករណ៍ FCDM បានរកឃើញដីព្រៃរិចរិលចំនួន ៩,៧៧៨ ហិកតា ក្នុងឆ្នាំ២០២៣ (រូបភាពទី២) ដែលមានការកើនឡើងចំនួន ១៩.៦% បើធៀបទៅនឹងឆ្នាំមុន។ ក្នុងអំឡុងខែសីហា ឆ្នាំ២០២៣ រដ្ឋាភិបាលកម្ពុជា បានសម្រេចពង្រីកផ្ទៃដីដែនជម្រកសត្វព្រៃឡង់ បន្ថែមសរុបចំនួន ៤៨៩,៦៦២ ហិកតា។

### ការបាត់បង់គម្របព្រៃឈើប្រចាំឆ្នាំ (ហិកតា) នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់




**↑ រូបភាពទី១៖**
ការបាត់បង់គម្របព្រៃឈើប្រចាំឆ្នាំ (ហិកតា) នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់។ ការបាត់បងគម្រប់ព្រៃឈើ៖ Hansen/UMD/Google/USGS/NASA

5 ទិន្នន័យដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ គឺផ្អែកលើព្រំប្រទល់ដំបូងរបស់តំបន់ការពារ មុនពេលបន្ថែមទិន្នន័យថ្មីៗនៅឆ្នាំ២០២៣នេះ។ វិធីសាស្ត្រនេះធានាបាននូវភាពស៊ីសង្វាក់គ្នាជាមួយនឹងទិន្នន័យឆ្នាំមុន ដែលអនុញ្ញាតិឱ្យមានការប្រៀបធៀបពីមួយឆ្នាំទៅមួយឆ្នាំយ៉ាងត្រឹមត្រូវ។




0 km
2.5 5 10

↑ រូបភាពទី២៖
ដែនជម្រកសត្វព្រៃ ព្រៃឡង់

1469 សកម្មភាព | 138 អាកាសធាតុ | 133 ផ្សេងៗ | 30 សេចក្តីរាយការណ៍

ដែនជម្រកសត្វព្រៃ ព្រៃឡង់បន្ថែម
ដែនជម្រកសត្វព្រៃ ព្រៃឡង់ មុនឆ្នាំ២០២៣
ការបាត់បង់គម្របព្រៃឈើ ឆ្នាំ២០២៣
ការរកឃើញដោយឧបករណ៍តាមដានការរំខានគម្របព្រៃឈើ ឆ្នាំ២០២៣

# ការបាត់បង់ព្រៃឈើ នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរកា និង សង្ឃ្សរុក្ខាវ័ន

## ដែនជម្រកសត្វព្រៃ ព្រះរកា

ដែនជម្រកសត្វព្រៃ ព្រះរកា បានបាត់បង់គម្របព្រៃឈើចំនួន ៥៧៥ ហិកតា នៅក្នុងឆ្នាំ២០២៣។ ចំនួននេះបង្ហាញឱ្យឃើញការកើនឡើងចំនួនជិត ៣៥% កើនេះតំណាងឱ្យការកើនឡើងជិត ៣៥% បើធៀបនឹងឆ្នាំមុន ដែលបណ្តាលឱ្យមានការបញ្ចេញឧស្ម័នឌីអុកស៊ីតស្មើនឹង ៣៩៣ គីឡូតោន ទៅក្នុងបរិយាកាស។ ចាប់តាំងពីឆ្នាំ២០០១មក ព្រៃព្រះរកា បានបាត់បង់គម្របព្រៃឈើសរុបចំនួន ៥,៤២០ ហិកតា ឬ ស្មើនឹង ៧% នៃផ្ទៃដីសរុប ដែលបណ្តាលឱ្យមានការបំភាយឧស្ម័នផ្ទះកញ្ចក់ចំនួនស្មើនឹង ៣.៧១ លានតោន (រូបភាពទី៣)។ ព្រៃព្រះរកាត្រូវបានប្រកាសផ្លូវការជា ដែនជម្រកសត្វព្រៃ ដែលមានទំហំចំនួន ៩០,៣៦១ ហិកតា ដោយក្រសួងបរិស្ថានក្នុងឆ្នាំ២០១៦។ គួរកត់សម្គាល់ថា ជាងពាក់កណ្តាលនៃការបាត់បង់គម្របព្រៃឈើសរុបចំនួន ៥៤% បានកើតឡើងចាប់តាំងពីឆ្នាំ២០១៨។

### ការបាត់បង់គម្របព្រៃឈើប្រចាំឆ្នាំ (ហិកតា) ក្នុងដែនជម្រកសត្វព្រៃព្រះរកា




↑ រូបភាពទី៣៖
ការបាត់បង់គម្របព្រៃឈើប្រចាំឆ្នាំ (ហិកតា) នៅក្នុងដែនជម្រកសត្វព្រៃ ព្រះរកា។ ការបាត់បងគម្រប់ព្រៃឈើ៖ Hansen/UMD/Google/USGS/NASA

**លើសពីនេះទៀត ឧបករណ៍ FCDM បានរកឃើញដីព្រៃរិចរិលចំនួន ៨៣២ ហិចតា (រូបភាពទី៤) ដែលកើនឡើងចំនួន ៤៥.២% បើធៀបនឹងឆ្នាំមុន។ ក្នុងអំឡុងខែសីហា ឆ្នាំ២០២៣ ដែនជម្រកសត្វព្រៃព្រះរកា ត្រូវបានដាក់បញ្ចូលគ្នាជាមួយដែនជម្រកសត្វព្រៃឆែប ដើម្បីបង្កើតជាដែនជម្រកសត្វព្រៃថ្មី ឆែប-ព្រះរកា។ តំបន់ថ្មីដែលស្ថិតនៅជាប់នឹងព្រំប្រទល់ភាគខាងជើងប្រទេស ឥឡូវនេះមានទំហំ ៣៤៧,៥៦៧ ហិកតា។**




0 km 3.75 15

↑ រូបភាពទី៤៖
ដែនជម្រកសត្វព្រៃ ព្រះរកា

135 សកម្មភាព | 36 អាកាសធាតុ | 35 ផ្សេងៗ | 8 សេចក្តីរាយការណ៍

ដែនជម្រកសត្វព្រៃថ្មី ឆែប | ព្រះរកា
ដែនជម្រកសត្វព្រៃ ព្រះរកា មុនឆ្នាំ២០២៣
ការបាត់បង់គ្រប់ព្រៃឈើ ឆ្នាំ២០២៣
ការរកឃើញដោយឧបករណ៍តាមដានការរំខានគម្របព្រៃឈើ

# ការបាត់បង់ព្រៃឈើ នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរកា និង សង្ឃរុក្ខាវ័ន

## ដែនជម្រកសត្វព្រៃ សង្ឃរុក្ខាវ័ន

ដែនជម្រកសត្វព្រៃ សង្ឃរុក្ខាវ័ន ដែលគេស្គាល់ថាជាព្រៃសហគមន៍សង្ឃរុក្ខាវ័ន បានបាត់បង់គម្របព្រៃឈើចំនួន ៤២ ហិកតា ក្នុងឆ្នាំ២០២៣។ ចំនួននេះបង្ហាញឱ្យឃើញពីការកើនឡើងចំនួន ៥០% បើធៀបនឹងឆ្នាំមុន ដែលបណ្តាលឱ្យមានការបញ្ចេញឧស្ម័នឌីអុកស៊ីតស្មើនឹងចំនួន ១៩,៣ គីឡូតោន ទៅក្នុងបរិយាកាស។ ចាប់តាំងពីឆ្នាំ២០០១មក ព្រៃសង្ឃរុក្ខាវ័ន បានបាត់បង់ផ្ទៃដីសរុបចំនួន ៥៥៦ ហិកតា ឬស្មើនឹង ៥.៤% នៃផ្ទៃដីសរុប ដែលបណ្តាលឱ្យមាន ការបំភាយឧស្ម័នផ្ទះកញ្ចក់ចំនួន ២៤៩ គីឡូតោន (រូបភាពទី៥)។ ព្រៃសង្ឃរុក្ខាវ័ន ត្រូវបានប្រកាសផ្លូវការជា ដែនជម្រកសត្វព្រៃ ដែលមានទំហំផ្ទៃដីចំនួន ៣០,២៥៤ ហិកតា ដោយក្រសួងបរិស្ថានក្នុងឆ្នាំ២០១៨។ គួរកត់សម្គាល់ថា ជាងពាក់កណ្តាលនៃការបាត់បង់គម្របព្រៃឈើសរុបចំនួន ៥៩% និងការបំភាយឧស្ម័ន ដែលពាក់ព័ន្ធបានកើតឡើងចាប់តាំងពីឆ្នាំ២០១៥។

លើសពីនេះទៅទៀត ឧបករណ៍ FCDM បានរកឃើញដីព្រៃរិចរិលចំនួន ៣៣៣ ហិកតា (រូបភាពទី៦) ដែលមានការថយចុះចំនួន ២១.៨% បើធៀបនឹងឆ្នាំមុន។ ដែនជម្រកសត្វព្រៃសង្ឃរុក្ខាវ័ន មិនរងផលប៉ះពាល់ដោយការផ្លាស់ប្តូរថ្មីៗក្នុងតំបន់ការពាររបស់ប្រទេសនោះទេ។

### ការបាត់បង់គម្របព្រៃឈើប្រចាំឆ្នាំ (ហិកតា) ក្នុងដែនជម្រកសត្វព្រៃសង្ឃរុក្ខាវ័ន




↑ **រូបភាពទី៥៖**
ការបាត់បង់គម្របព្រៃឈើប្រចាំឆ្នាំ (ហិកតា) នៅក្នុងដែនជម្រកសត្វព្រៃ សង្ឃរុក្ខាវ័ន។ ការបាត់បងគម្របព្រៃឈើ៖ Hansen/UMD/Google/USGS/NASANASA




0 0.75 1.5 3 km

↑រូបភាពទី៦
ដែនជម្រកសត្វព្រៃ សង្ឃរុក្ខាវ័ន

7 សកម្មភាព | 1 អាកាសធាតុ | 5 ផ្សេងៗ | 0 សេចក្ដីរាយការណ៍

ដែនជម្រកសត្វព្រៃសង្ឃរុក្ខាវ័ន
ការបាត់បង់គម្រប់ព្រៃឈើ ឆ្នាំ២០២៣
ការរកឃើញដោយឧបករណ៍តាមដានការរំខានគម្របព្រៃឈើ ឆ្នាំ២០២៣

ការកំណត់ជាដែនជម្រកសត្វព្រៃនៅកម្ពុជា គឺមានគោលបំណង ដើម្បីការពារជីវចម្រុះ លើកកម្ពស់ការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព និងគាំទ្រដល់ការសិក្សាស្រាវជ្រាវ និងការអប់រំផ្នែកវិទ្យាសាស្ត្រ។ ទោះជាយ៉ាងនេះក៏ដោយ ទិន្នន័យបង្ហាញថាការបាត់បង់គម្របព្រៃឈើដ៏សំខាន់បានកើតឡើងនៅក្នុងតំបន់ការពារទាំងនេះ ចាប់តាំងពីការកំណត់ជាដែនជម្រកសត្វព្រៃ ដែលវាបង្កើនការព្រួយបារម្ភអំពីប្រសិទ្ធភាពនៃការការពារព្រៃទាំងនេះ។

**គួរកត់សម្គាល់ថា ការបាត់បង់គម្របព្រៃឈើ ការរិចរិលព្រៃឈើ និងការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលពាក់ព័ន្ធភាគច្រើនបានកើតឡើងក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដោយបានគូសបញ្ជាក់ពីតម្រូវការសម្រាប់វិធានការអភិរក្ស និងការអនុវត្តដ៏តឹងរឹងបន្ថែមទៀតដើម្បីការពារដែនជម្រកដ៏សំខាន់ទាំងនេះ។**

# » បញ្ហាប្រឈមនៅមូលដ្ឋាន

## ភស្តុតាងបទល្មើស និងការបដិសេធរបស់អាជ្ញាធរ នៅតែបន្តកើតមានឡើង

នៅអំឡុងចុងខែមីនា ឆ្នាំ២០២៣ ក្រុមសកម្មជនការពារព្រៃឈើបានចំណាយពេល៤ថ្ងៃ ៣យប់ ចុះស៊ើបអង្កេតតំបន់មួយ នៅក្នុងខេត្តព្រះវិហារ។ ពួកគេបានរកឃើញការកាប់ដើមឈើខុសច្បាប់ជាង ២០០ដើម។ តំបន់នេះបានបង្ហាញសញ្ញានៅក្នុងរយៈពេលប្រតិបត្តិការមាន ឡានដឹកឈើធំៗ ម៉ូតូ និងសន្និសុខប្រដាប់អាវុធ ខណៈដែលសាក្សីអាចកំណត់អត្តសញ្ញាណស្លាកសញ្ញារបស់ក្រុមហ៊ុន ម៉ាខលឡូជីស្ទិក (Macle Logistics (Cambodia) Co., Ltd) ដែលមានមូលដ្ឋាននៅទីក្រុងភ្នំពេញ។ សកម្មជនកត់សម្គាល់ថា ជាអកុសលអាជ្ញាធររដ្ឋាភិបាលមិនបានចាត់វិធានការប្រកបដោយប្រសិទ្ធភាពចំពោះប្រតិបត្តិការកាប់ឈើ និងមិនទប់ស្កាត់ការនាំចេញឈើខុសច្បាប់ទៅកាន់ប្រទេសវៀតណាម ដែលជាអ្នកទិញឈើប្រណីតដ៏សំខាន់[6]។

បន្ថែមលើសពីនេះ ការស៊ើបអង្កេតមួយដែលធ្វើឡើងដោយបណ្តាញយុវជនកម្ពុជា (CYN) បានបង្ហាញពីករណីការកាប់ឈើខុសច្បាប់ចំនួន ១២៩ ករណី កើតឡើងក្នុងរយៈពេល ៣ថ្ងៃ កាលពីខែឧសភា ឆ្នាំ២០២៣។ ការស៊ើបអង្កេតរបស់ CYN បានបង្ហាញថា ព្រៃស្រោង និងបៃតងគ្រប់រដូវកាល ជាច្រើនរយហិកតា ត្រូវបានឈូសឆាយ ហើយដើមឈើរាប់រយដើមត្រូវបានបាញ់សញ្ញាសម្គាល់ សម្រាប់កាប់រំលំនាពេលអនាគត។ CYN បានកត់សម្គាល់ថា ស្ថានការណ៍នៅតែជាកង្វល់ និងបានអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជា ចាត់វិធានការប្រឆាំងនឹងការទន្ទ្រាន និងទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើបន្ថែមទៀតនៅក្នុងព្រៃឡង់។ អាជ្ញាធរបានបដិសេធម្តងទៀតថា មិនមានសកម្មភាពបទល្មើសធ្ងន់ធ្ងរបែបនេះឡើយ[7]។.



← រូបភាពទី ៧
សេចក្តីរាយការណ៍ពីភស្តុតាងបទល្មើសខុសច្បាប់នៅក្នុងខេត្តព្រះវិហារ
ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣

6 សកម្មជនរកឃើញភស្តុតាងបទល្មើសខុសច្បាប់នៅក្នុងតំបន់ការពារ នៅភាគខាងជើងប្រទេសកម្ពុជា -វិទ្យុអាស៊ីសេរី ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣
Radio Free Asia, 4 April 2023

7 អាជ្ញាធរបដិសេធរបាយការណ៍ស្តីពីបទល្មើសខុសច្បាប់នៅក្នុងព្រៃឡង់របស់CYN - ខ្មែរថាម ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣- Khmer Times, 16 May 2023

# ការពង្រីកដែនជម្រកសត្វព្រៃ - យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន

ថ្មីៗនេះ រដ្ឋាភិបាលកម្ពុជាបានពង្រីកតំបន់ការពាររបស់ប្រទេស ជាងមួយលានហិកតា តាមរយៈអនុក្រឹត្យជាបន្តបន្ទាប់។ ទោះជាយ៉ាងនេះក៏ដោយ ដីតំបន់ការពារថ្មីៗភាគច្រើនហាក់ដូចជាដីនៅជិតតំបន់ការពារស្រាប់ ដែលមានជាទីជម្រក និងស្រែចំការតាំងនៅរួចហើយ។

វិធានការនេះត្រូវបានទទួលការមន្ទិលសង្ស័យពីក្រុមសង្គមស៊ីវិល និងសកម្មជនដោយសារកង្វះការពិគ្រោះយោបល់ និងបញ្ហាដែលកំពុងកើតឡើងដោយសារការកាប់បំផ្លាញព្រៃឈើ និងការធ្វើឯកជនភាវូបនីយកម្មក្នុងតំបន់ការពារទាំងនេះ។

សមត្ថភាពរបស់អាជ្ញាធរក្នុងកិច្ចការល្បាតតំបន់ដីធំធេងទាំងនេះ វាក៏ជាចម្ងល់ផងដែរ ជាពិសេសបានបង្ហាញឱ្យឃើញពីការអនុវត្តច្បាប់មិនមានប្រសិទ្ធភាព នៅក្នុងតំបន់ការពារដែលមានស្រាប់។ ទិន្នន័យមិនពេញលេញ និងផែនទីដែលបាត់បង់ បានធ្វើឱ្យអ្នកអភិរក្សមានការភ័ន្តច្រឡំ ដែលធ្វើឱ្យវាពិបាកក្នុងការស្វែងយល់អំពីផលប៉ះពាល់ពេញលេញនៃការផ្លាស់ប្តូរទាំងនោះ។

រដ្ឋាភិបាលបានបញ្ជាក់ថា វិធីសាស្ត្រកំណត់តំបន់គ្រប់គ្រងឡើងវិញ មានគោលបំណងបញ្ចៀសជម្លោះដីធ្លី និងបង្កើតព្រំប្រទល់ច្បាស់លាស់ ប៉ុន្តែក្តីបារម្ភនៅតែមានអំពីចេតនាក៏ដូចជាប្រសិទ្ធភាពនៃការការពារ និងការគ្រប់គ្រង ដោយសារធនធានមានកម្រិត និងសកម្មភាពកាប់ឈើខុសច្បាប់ដែលកំពុងបន្តកើតមាន។ ក្រុមអ្នកអភិរក្ស និងក្រុមសហគមន៍បានត្រៀមខ្លួនរួចរាល់ ដើម្បីគាំទ្រដល់ក្រសួងបរិស្ថាន ដោយសង្កត់ធ្ងន់លើតម្រូវការសម្រាប់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការចូលរួមរបស់សហគមន៍នៅក្នុងតំបន់ការពារថ្មីៗទាំងនោះ[8]។

នៅទីបំផុត យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានថ្មី (CES) ២០២៣-២០២៨ ត្រូវបានដាក់ឱ្យដំណើរការនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣។ វិធីសាស្ត្រនេះសង្កត់ធ្ងន់លើអាទិភាពសំខាន់ៗចំនួនបីគឺ ភាពស្អាត ភាពបៃតង និងចីរភាព ដែលមានគោលបំណងប្រែក្លាយកម្ពុជាឆ្ពោះទៅរកអព្យាក្រឹតភាពកាបូន។ វារួមបញ្ចូលទាំងវិធានការសម្រាប់ការគ្រប់គ្រងការបំពុល ការដាំដើមឈើ និងការគ្រប់គ្រងធនធានធម្មជាតិ ដោយមានគោលដៅបង្កើនគម្របព្រៃឈើដល់ចំនួន ៦០% នៅឆ្នាំ២០៥០[9]។ ដើម្បីគ្រប់គ្រងធនធានធម្មជាតិ និងអភិរក្សជីវចម្រុះ ប្រកបដោយប្រសិទ្ធភាព ក្រសួងបានអំពាវនាវជាផ្លូវការ នូវវិធានការចំនួនបួនដែលត្រូវអនុវត្ត៖ ១. ការរឹតបន្តឹងការអនុវត្តច្បាប់ប្រឆាំងបទល្មើសធនធានធម្មជាតិ ២. កិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់បទល្មើសនានា ៣. ភាពជាដៃគូជាមួយអង្គភាពប្រឆាំងអំពើពុករលួយ (ACU) និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីពង្រឹងការអនុវត្តច្បាប់ និង៤. រៀបចំផែនការដាំដើមឈើដើម្បីស្តារព្រៃឈើឡើងវិញ និងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព[10]។ ស្របពេលដែល CES ២០២៣-២០២៨ កំណត់គោលដៅប្រកបដោយមហិច្ឆិតាសម្រាប់អនាគតបរិស្ថានរបស់កម្ពុជា យើងត្រូវរង់ចាំមើលថា តើវិធានការទាំងនេះនឹងផ្តល់លទ្ធផលដូចអ្វីដែលគេចង់បានឬយ៉ាងណា ដូច្នេះវាមានសារៈសំខាន់ណាស់ក្នុងការឈានទៅរកគំនិតផ្តួចផ្តើមថ្មីៗទាំងនេះ ប្រកបដោយសុទិដ្ឋិនិយមនិងប្រុងប្រយ័ត្ន។



→ **រូបភាពទី ៨**
សេចក្តីរាយការណ៍ពីភស្តុតាងនៃការធ្វើឯកជនភាវូបនីយកម្មដីធ្លី នៅភូមិព្រៃស្រុកចាស់ ខេត្តព្រះវិហារ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៣

[8] មន្ទិលចំពោះការពង្រីកតំបន់ការពារជាងមួយលានហិកតារបស់កម្ពុជា - Mongabay ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣- Mongabay, 29 August 2023

[9] ក្រសួងដាក់ចេញនូវយុទ្ធសាស្ត្រ "មហិច្ឆតា" សម្រាប់អព្យាក្រឹតភាពកាបូន - ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ - Phnom Penh Post, 13 November 2023

[10] វិធានការទប់ស្កាត់ឧក្រិដ្ឋកម្មធនធានធម្មជាតិ - ក្រសួងបរិស្ថាន ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣Resource Crimes - Ministry of Environment, 17 October 2023

# ក្រុមហ៊ុន Think Biotech - ផ្លូវថ្មីៗសម្រាប់ការកាប់ឈើ



↑ រូបភាពទី ៩
ការសាងសងផ្លូវថ្មីពីសម្បទានក្រុមហ៊ុន Think Biotech នៅភាគខាងកើតដែនជម្រកសត្វព្រៃ ព្រៃឡង់។ ខែមេសា ឆ្នាំ២០២៣។ រូបភាពផ្កាយរណប ពីខែមេសា ឆ្នាំ២០២៣។ ដំបន់ដែលមានពណ៌ក្រហមកំណត់ព្រំដែនរបស់សម្បទានក្រុមហ៊ុន Think Biotech។ ពណ៌បៃតងគឺជាដែនជម្រកសត្វព្រៃ ព្រៃឡង់។ កូអដោយនេចំនុចកណ្តាល៖ 13.01047N, 105.87197E. Planet Labs PBC, CC BY-NC-SA 2.0

ការស៊ើបអង្កេតមួយរបស់ Mongabay បានបង្ហាញថា មានផ្លូវមួយខ្សែដែលរត់ចេញពីដីសម្បទានស្តារព្រៃឈើឡើងវិញ ចូលទៅក្នុងបេះដូងនៃដែនជម្រកសត្វព្រៃព្រៃឡង់ ក្នុងប្រទេសកម្ពុជា ហើយផ្លូវនេះហាក់ដូចជាជួយសម្រួលដល់ការកាប់ឈើខុសច្បាប់ និងការជួញដូរឈើមានតម្លៃ។ ផ្លូវដែលត្រូវបានរកឃើញដំបូងដោយរូបភាពផ្កាយរណប ចន្លោះពីថ្ងៃទី៦ ដល់ទី៩ ខែមេសា មានប្រវែង ១២ គីឡូម៉ែត្រ និងមានប្រភពចេញពីដីសម្បទាន Think Biotech។ ទោះបីជាក្រុមហ៊ុនធ្លាប់ជាប់ពាក់ព័ន្ធក្នុងបទល្មើសព្រៃឈើក៏ដោយ នាយកក្រុមហ៊ុននេះបដិសេធថា មិនមានជាប់ពាក់ព័ន្ធនោះទេ[11]។

លើសពីនេះ អ្នកសរសេររបាយការណ៍នេះបានបង្ហាញផ្លូវថ្មីមួយទៀតដែលមានចម្ងាយ ៣ គីឡូម៉ែត្រ កំពុងត្រូវបានបើកដំណើរការ ពីផ្នែកខាងក្រោមដីសម្បទាន Think Biotech។ ផ្លូវថ្មីនេះក៏ត្រូវបានគេរកឃើញដោយរូបភាពពីផ្កាយរណបផងដែរនោះ កំពុងតភ្ជាប់ទៅកាន់អង្កត់ទ្រូងផ្លូវប្រសព្វនឹងផ្លូវធំ នៅភាគអាគ្នេយ៍នៃដែនជម្រកសត្វព្រៃព្រៃឡង់។ អង្កត់ទ្រូងផ្លូវប្រសព្វចូលកាន់តែជ្រៅបន្ថែមទៀតដែលមានចម្ងាយ ៨.៥ គីឡូម៉ែត្រ ត្រូវបានបើកដំណើរការផងដែរនៅក្នុងខែមេសា ហើយឆ្លងកាត់តាមដីសម្បទានស៊ីម៉ងត៍ KP និងត្រង់ចូលទៅក្នុងបេះដូងនៃតំបន់ការពារ[12]។

ជាលទ្ធផល សមត្ថកិច្ចបានចុះបង្រ្កាប[13] កាលពីថ្ងៃទី៣ ឧសភា ឆ្នាំ២០២៣។ មន្ទីរខេត្តក្រចេះ សហការជាមួយគណៈកម្មាធិការជាតិទប់ស្កាត់បទល្មើសព្រៃឈើ (NCFCP) បានកំណត់អត្តសញ្ញាណក្រុមហ៊ុនឯកជនពាក់ព័ន្ធនឹងការរត់ពន្ធឈើនៅក្បែរដែនជម្រកសត្វព្រៃ។ បើទោះជាក្រុមហ៊ុនមិនបញ្ចេញឈ្មោះផ្ទាល់ក៏ដោយ ក៏គេបញ្ជាក់ថា ក្រុមហ៊ុននោះកាន់កាប់តំបន់ដីសម្បទានសេដ្ឋកិច្ច ដែលបង្កភាពងាយស្រួលដល់ឈ្មួញក្នុងការកាប់ឈើខុសច្បាប់ និងលក់ឈើឲ្យអង្គភាពមួយនេះ។

របាយការណ៍មួយពីអង្គភាពដដែលបានបង្ហាញថា មនុស្ស ១២ នាក់ត្រូវបានចាប់ខ្លួន ហើយឈើចំនួន ៣២៨,៧៩១ ម៉ែត្រគូប ត្រូវបានរឹបអូស។ ខណៈដែលមនុស្សចំនួន ១១ នាក់ ក្នុងចំណោមអ្នកដែលត្រូវបានចាប់ខ្លួនត្រូវបានបញ្ជូនទៅតុលាការដើម្បីបន្តនីតិវិធី សកម្មជននិយាយថា នេះគ្រាន់តែជាការបង្ហាញ និងកំពុងកំណត់គោលដៅអ្នកកាប់ឈើតូចតាច ខណៈដែលថៅកែធំៗនៅមានសេរីភាព។ អាជ្ញាធរបានប្រកាសថា យុទ្ធនាការនឹងបន្ត។ ទោះយ៉ាងណាក៏ដោយ មិនមានព័ត៌មានបន្ថែមអំពីបញ្ហានេះ ឬច្បាប់ថតចម្លងរបស់របាយការណ៍នោះទេ។ ទីបំផុតកាលពីថ្ងៃទី៩ ខែតុលា ឆ្នា២០២៣ ក្រសួងបរិស្ថានបានបដិសេធថា គ្មានផ្លូវថ្មីណាមួយមិនត្រូវបានសាងសង់ក្នុងដែនជម្រកសត្វព្រៃឡង់ ដើម្បីដឹកជញ្ជូនឈើខុសច្បាប់នោះទេ បើទោះបីជាអាចមើលឃើញពីផ្កាយរណបក៏ដោយ[14]។



↑ រូបភាពទី១០
ការសាងសងផ្លូវទីពីរនៅផ្នែកខាងលើក្រុមហ៊ុន ស៊ីម៉ង់ KP នៅកណ្តាលដែនជម្រកសត្វព្រៃ ព្រៃឡង់។ រូបភាពផ្កាយរណប ពីខែមេសា ឆ្នាំ២០២៣។ តំបន់ដែលមានពណ៌ក្រហមកំណត់ពីព្រំដែនរបស់ក្រុមហ៊ុន Think Biotech។ ពណ៌បៃតង គឺនៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់។ កូអដោនេចំនុចកណ្តាល៖ 13.01579 N, 105.83021 E. Planet Labs PBC, CC BY-NC-SA 2.0

[11] ផ្លូវកាប់ឈើកាត់ចូលទៅក្នុងព្រៃឡង់របស់កម្ពុជា ពីសម្បទានរបស់ក្រុមហ៊ុន Think Biotech Mongabay ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣- Mongabay, 5 October 2023

[12] របាយការណ៍បច្ចុប្បន្នភាពព្រៃឡង់ត្រីមាសទី៩ និងទី១០ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ Quarterly Update #9 and #10, 16 October 2023

[13] ក្រុមហ៊ុនឯកជនត្រូវបានរកឃើញថា ជាប់ពាក់ព័ន្ធបទល្មើសខុសច្បាប់នៅក្នុងព្រៃឡង់ - ខ្មែរថាម ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ - Khmer times, 5 May 2023

[14] ក្រសួងច្រានចោលការចោទប្រកាន់ពីការសាងសងផ្លូវ និងការកាប់ឈើនៅក្នុងដែនជម្រកសត្វព្រៃ - ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ - Phnom Penh Post, 9 October 2023

# ប្រតិបត្តិការរុករករ៉ែក្នុងដែនជម្រកសត្វព្រៃព្រៃឡង់

នៅក្នុងខែតុលា ឆ្នាំ២០២៣ របាយការណ៍ថ្មីមួយត្រូវបានចេញផ្សាយ ដែលបង្ហាញពីប្រតិបត្តិការរុករករ៉ែមាសនៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់។ របាយណ៍ត្រូវបានធ្វើឡើងដោយក្រុមស៊ើបអង្កេតការរុករករ៉ែមាស និងចេញផ្សាយដោយអង្គការបរិស្ថានរបស់ប្រទេសស្វីសឈ្មោះ Bruno Manser Fonds[15]។



**រូបភាពទី ១១**
សេចក្តីរាយការណ៍ពីសកម្មភាពរុករករ៉ែ នៅតំបន់អូរផ្ការ ជិតភូមិស្រែព្រើង ខេត្តកំពង់ធំ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៣

របាយការណ៍បានតាមដានការវិវត្តន៍ នៃការជីកយករ៉ែមាសនៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ ពីការជីកយករ៉ែជាលក្ខណៈទ្រង់ទ្រាយតូចនៅតំបន់ជុំវិញភូមិស្នួងអន និងភ្នំជី រហូតដល់ប្រតិបត្តិការពាណិជ្ជកម្មទ្រង់ទ្រាយធំ។ ក្រុមហ៊ុន Late Cheng Development បានទទួលអាជ្ញាប័ណ្ណរុករកក្នុងខែមីនា ឆ្នាំ២០២០ លើផ្ទៃដីចំនួន ១៥,១០០ ហិកតា ឬស្មើនឹង ៣៧,៣០០ acres នៃដែនជម្រកសត្វព្រៃឡង់ និងអាជ្ញាប័ណ្ណជីកយករ៉ែនៅខែកញ្ញា ឆ្នាំ២០២២។ ទោះជាយ៉ាងនេះក៏ដោយ អ្នកស្រុកនិយាយថា ក្រុមហ៊ុននេះបានដំណើរការដោយគ្មានអាជ្ញាប័ណ្ណពាក់ព័ន្ធតាំងពីឆ្នាំ២០១៩មកម្លេះ។ ការចោទប្រកាន់ក៏បង្ហាញផងដែរថា ប្រតិបត្តិការរុករករ៉ែអាចបំពានច្បាប់ជាច្រើន ដោយមិនមានការវាយតម្លៃផលប៉ះពាល់បរិស្ថាន ជាសាធារណៈដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃសកម្មភាពរបស់ខ្លួន[16]។

ទោះបីជាមានភាពស្របច្បាប់ក្នុងប្រតិបត្តិការរុករករ៉ែមាសនៅក្នុងដែនជម្រកសត្វព្រៃអាចត្រូវបានដាក់ទណ្ឌកម្មដោយការវាយតម្លៃផលប៉ះពាល់បរិស្ថានក៏ដោយ ពិតណាស់វាគឺមិនគ្រប់គ្រាន់នោះទេ ដោយសារសកម្មភាពបំផ្លាញបរិស្ថានដែលកំពុងកើតមាននៅក្នុងដីសម្បទានរបស់ក្រុមហ៊ុន Late Cheng។ សារធាតុ Cyanide ដែលកំពុងត្រូវបានប្រើប្រាស់ដើម្បីទាញយកមាសពីអណ្តូងរ៉ែ ដែលគេស្គាល់យ៉ាងច្បាស់ថាបង្កហានិភ័យដល់បរិស្ថាន និងសុខភាពមនុស្ស ហើយមានពាក្យចចាមអារ៉ាមដែលមិនមានការបញ្ជាក់អំពីការស្លាប់របស់កម្មករ និងលក្ខខណ្ឌការងារមិនល្អនៅក្នុងអណ្តូងរ៉ែ ដែលចោទជាសំណួរអំពីសុវត្ថិភាពកម្មករ និងការអនុវត្តរបស់ក្រុមហ៊ុន[17]។ ប្រតិបត្តិការរុករករ៉ែកំពុងគំរាមកំហែងដល់ប្រភេទសត្វដែលជិតផុតពូជ ដូចជាសត្វខ្ទីង និងសត្វទោច ដែលពឹងផ្អែកលើព្រៃលូតលាស់ចាស់ក្នុងដែនជម្រកសត្វព្រៃ ។ នៅទីបំផុតការអភិវឌ្ឍន៍នៅក្នុងតំបន់ដីសម្បទានរ៉ែរបស់ក្រុមហ៊ុន Late Cheng បានទាមទារការកាប់ឆ្ការព្រៃរាប់រយហិកតា និងសាងសង់ផ្លូវសមស្របចូលក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ ដែលធ្វើឱ្យមានការទន្ទ្រានរបស់មនុស្ស និងការបែកខ្ញែកទីជម្រករបស់សត្វបន្ថែមទៀត។ ការពង្រីកនេះបានរឹតបន្តឹងការចេញចូលទៅកាន់ភូមិ បង្កើនការភ័យខ្លាចចំពោះការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងនាំឱ្យមានការចោទប្រកាន់ពីការឃុបឃិតរបស់រដ្ឋាភិបាលជាមួយក្រុមហ៊ុនរុករករ៉ែ[18]។

ជាការឆ្លើយតប លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានយល់ព្រមលើការផ្អាកអាជ្ញាប័ណ្ណរុករករ៉ែថ្មីមួយ នៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល លោក កែវ រតនៈ[19]។ ទោះជាយ៉ាងណា បើទោះជាមានការផ្អាកក៏ដោយ ក្រុមហ៊ុនដែលមានលិខិតអនុញ្ញាតស្រាប់អាចបន្តប្រតិបត្តិការនៅក្នុងទីតាំងរបស់ពួកគេបាន។ នៅក្នុងចំណោមនោះមាន ក្រុមហ៊ុន គ្លូប៊ល ហ្វ្រីន (ខេមបូឌា) អេនើជី ឌីវេឡុបមេន ដែលភ្ជាប់ជាមួយក្រុមហ៊ុន ទ្រីភាព។ ក្រុមហ៊ុនរបស់ឧកញ៉ាដ៏លេចធ្លោនេះ (ដែលធ្លាប់ជាប់ពាក់ព័ន្ធជាមួយប្រតិបត្តិការកាប់ឈើខុសច្បាប់ និងរងទណ្ឌកម្មរបស់សហរដ្ឋអាមេរិកក្នុងឆ្នាំ២០១៩) បានទទួលរង្វាន់ដីចំនួន ២៨,០០០ ហិកតា នៅខេត្តព្រះវិហារភាគខាងជើង ក្នុងគោលបំណងជីកយករ៉ែដែក[20]។

[15] ការរុករករ៉ែមាសទ្រង់ទ្រាយធំ គម្រាមកំហែងដែនជម្រកសត្វព្រៃកម្ពុជា - Bruno Manser-Fonds ខែតុលា ឆ្នាំ២០២៣- Bruno Manser-Fonds, October 2023

[16] កម្មករជីករ៉ែមាសរបស់ចិន "ដោយខុសច្បាប់" កំពុងបំផ្លាញដែនជម្រកសត្វព្រៃកម្ពុជា - Mongabay ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ - Mongabay, 7 December 2023

[17] ការពង្រីកការជីកយករ៉ែមាសក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ - ព័ត៌មានខេមបូចា ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣- CamboJA News, 20 October 2023

[18] ក្រុមហ៊ុនរុករករ៉ែមាស កំពុងបំផ្លាញដែនជម្រកសត្វព្រៃកម្ពុជា - ព័ត៌មាន VOA ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ - VOA news, 28 October 2023

[19] លោក រតនៈ មានប្រសាសន៍ថា នាយករដ្ឋមន្ត្រីយល់ព្រមលើការផ្អាកការជីកយករ៉ែនៅព្រៃឡង់ - ខ្មែរថាម ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣- Khmer Times, 23 November 2023

[20] មេឈ្មួញឈើដែលជាប់ទណ្ឌកម្ម ទទួលបានសម្បទានរ៉ែមាសថ្មីនៅក្នុងព្រៃឡង់របស់កម្ពុជា - Mongabay ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤- Mongabay, 23 January 2024

# » ការឃ្លាំមើលរបស់សហគមន៍

## បណ្តាញសហគមន៍ព្រៃឡង់



PLCN

↑ **រូបភាពទី ១២**
ការឃ្លាំមើលព្រៃឈើរបស់សហគមន៍នៅព្រះវិហារ។
ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣

ត្រូវបានបង្កើតឡើងនៅអំឡុងឆ្នាំ២០០០ បណ្តាញសហគមន៍ព្រៃឡង់ (PLCN) គឺជាសម្ព័ន្ធសហគមន៍មូលដ្ឋាន នៅជុំវិញដែនជម្រកសត្វព្រៃ ព្រៃឡង់។ គោលដៅចម្បងរបស់បណ្តាញ គឺដើម្បីចងក្រងឯកសារ ប្រយុទ្ធប្រឆាំងការកាប់ឈើខុសច្បាប់ និងបទល្មើសព្រៃឈើផ្សេងៗទៀត។ PLCN ទទួលបានការសាទរជាអន្តរជាតិចំពោះកិច្ចខិតខំប្រឹងប្រែងអភិរក្សដីផ្ទើមរបស់ខ្លួន និងបានទទួលពានរង្វាន់បរិស្ថានដ៏មានកិត្យានុភាពជាច្រើន។ បើទោះបីជាមានសមិទ្ធផលសំខាន់ៗយ៉ាងនេះក៏ដោយ ក៏សមាជិក PLCN ប្រឈមមុខនឹងការយាយី និងការចាប់ខ្លួនជាបន្តបន្ទាប់ដោយអាជ្ញាធរ។ នៅក្នុងឆ្នាំ២០២០ មន្ត្រីបានហាមឃាត់ PLCN មិនឱ្យចុះល្បាតព្រៃ នៅក្នុងដែនជម្រកសត្វ ដែលនាំឲ្យមានការកើនឡើងយ៉ាងខ្លាំងក្លា នៃសកម្មភាពកាប់បំផ្លាញឈើដោយខុសច្បាប់។

ទោះបីជាមានបញ្ហាប្រឈមទាក់ទងនឹងការចេញចូល និងអាស្រ័យផលនៅក្នុងព្រៃតាមទម្លាប់ក៏ដោយ ក៏សហគមន៍ព្រៃឡង់បានបង្ហាញពីការចូលរួមឃ្លាំមើលព្រៃមានចំនួនកើនឡើង នៅក្នុងដែនជម្រកសត្វព្រៃ។

**នៅឆ្នាំ២០២៣ PLCN បានកត់ត្រាទិន្នន័យសរុបចំនួន ៨,៤២៨ ទិន្នន័យ ដែលកើនឡើងជិត ១៣០% បើធៀបនឹងឆ្នាំមុន (រូបភាពទី៧)។ ចំណុចសំខាន់ៗរួមមាន៖**




## ប្រភេទ "ធនធាន"

មានចំនួន ៧២% ស្មើនឹង ៦,០៣៩ ទិន្នន័យ នៃការឃ្លាំមើលសរុប។ ការរកឃើញដ៏សំខាន់បំផុត គឺដើមឈើប្រណីត មានចំនួន ៣,៤២៦ ទិន្នន័យ និងដើមច្បោះមានចំនួន ៩៥៥ ទិន្នន័យ។ អនុផលព្រៃឈើ (NTFPs) ត្រូវបានរាយការណ៍ចំនួន ១,៣២៩ ទិន្នន័យ។ សត្វព្រៃមានចំនួន ៥៣៧ ទិន្នន័យ និងទីតាំងពិសិដ្ឋ ឬទីតាំងធ្វើពិធីបុណ្យផ្សេងៗ ដូចជាកន្លែងបញ្ចុះសព និងការបំប្លួសដើមឈើត្រូវបានរាយការណ៍តិចតួច ដែលមានចំនួន ១០៨ ទិន្នន័យ (រូបភាពទី៨)។




## ប្រភេទ "សកម្មភាព"

មានចំនួនប្រហែល ២៤% ស្មើនឹងចំនួន ២,០១០ ទិន្នន័យ នៃចំនួនទិន្នន័យឃ្លាំមើលសរុបប្រចាំឆ្នាំ ដែលមានចំនួនជិតពីរដង បើធៀបនឹងឆ្នាំមុន។ ជាង ៩៥% នៃទិន្នន័យទាំងនេះទាក់ទងនឹងការកាប់ឈើខុសច្បាប់ ខណៈដែល ៥% នៃការចងក្រងទិន្នន័យ គឺស្តីអំពីសកម្មភាពខុសច្បាប់ពាក់ព័ន្ធនឹងការជីកយករ៉ែ នៅក្នុងដែនជម្រកសត្វព្រៃ គឺស្មើនឹង ២០ ទិន្នន័យ ដីសម្បទានសេដ្ឋកិច្ច (ELC) មានចំនួន ១២ ទិន្នន័យ និងការបរបាញ់ខុសច្បាប់ ការប្រើប្រាស់កាំភ្លើងកែច្នៃ និងអន្ទាក់ សត្វ មានចំនួន ៣៥ ទិន្នន័យ។ **សេចក្តីរាយការណ៍នៅក្នុងប្រភេទ "សកម្មភាព" បានបង្ហាញចំនួន ១,០១៦ ករណី ជាដង្កត់ឈើទោល នៃឈើប្រណីត និងចំនួន ៤១៤ ទិន្នន័យ ទាក់ទងនឹងការដឹកជញ្ជូន និងទីតាំងស្តុកឈើខុសច្បាប់។ លើសពីនេះទៀត មានការកត់ត្រាពីការកាប់រានព្រៃចំនួន ២២៩ ទិន្នន័យ និងចំនួន ២៧០ ទិន្នន័យជាគំនរឈើ (រូបភាពទី៩)។**




## ប្រភេទដែលនៅសល់មានចំនួន

៤% នៃសកម្មភាពឃ្លាំមើលសរុប។ អ្នកដើរល្បាតបានរាយការណ៍ទិន្នន័យដែលទាក់ទងនឹងអាកាសធាតុមានចំនួន ១៦៨ ទិន្នន័យ រួមទាំងខ្យល់ព្យុះ ភ្លើងឆេះព្រៃ និងការផ្លាស់ប្តូរទេសភាពក្នុងតំបន់ ក៏ដូចជាសកម្មភាពរបស់ PLCN ដូចជាសិក្ខាសាលា និងរូបថតក្នុងពេលល្បាត។ លើសពីនេះ មានចំនួន ៤៣ ទិន្នន័យ ដែលរាយការណ៍អំពីអន្តរកម្មរវាងអ្នកល្បាត និងអាជ្ញាធរ ដែលមួយចំនួនពាក់ព័ន្ធនឹងការបំភិតបំភ័យ និងការគំរាមកំហែងដល់សមាជិកល្បាត។




## ប្រភេទទូទៅ

←រូបភាពទី៧៖
ការឃ្លាំមើលរបស់ PLCN ដោយបានកត់ត្រាទិន្នន័យ ប្រភេទសំខាន់ៗ នៅក្នុងឆ្នាំ២០២៣។




## បទល្មើស

→រូបភាពទី៩៖
ការឃ្លាំមើលរបស់ PLCN ដោយបានកត់ត្រាទិន្នន័យនៅក្នុងឆ្នាំ២០២៣។ ជាប្រភេទការកាប់ឈើ៖




## ធនធាន

←រូបភាពទី៨៖
ការឃ្លាំមើលរបស់ PLCN ដោយបានកត់ត្រាទិន្នន័យនៅក្នុងឆ្នាំ២០២៣។ ជាប្រភេទធនធានផ្សេងៗ៖



**រូបភាពទី ១៦**
សេចក្ដីរាយការណ៍ពីការដឹកជញ្ជូនឈើនៅក្នុងខេត្តក្រចេះ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣

# » ការឃ្លាំមើលរបស់សហគមន៍

## បណ្ដាញសហគមន៍ព្រៃព្រះរកា

↓រូបភាពទី ១៧
ការចុះល្បាតរបស់សហគមន៍ព្រះរកា ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣



# PFCN

បណ្ដាញសហគមន៍ព្រៃព្រះរកា (PFCN) គឺជាសម្ព័ន្ធដែលមានសហគមន៍មកពីភូមិចំនួន ២២ ដែលមានអ្នកភូមិប្រហែល ២០,០០០ នាក់ ពឹងផ្អែកលើព្រៃព្រះរកាសម្រាប់របរចិញ្ចឹមជីវិតរបស់ពួកគេ។ បណ្ដាញនេះរួមមានទាំងជនជាតិដើមភាគតិចកួយ និងប្រជាជនទូទៅ ដែលសុទ្ធតែមានគោលបំណងដើម្បីការពារដែនជម្រកសត្វព្រៃព្រះរកា។ ពួកគេធ្វើការល្បាតព្រៃជាទៀងទាត់ ដើម្បីកត់ត្រាការបាត់បង់ព្រៃឈើ ការផ្លាស់ប្ដូរជីវចម្រុះ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ លើសពីនេះទៀត ក្រុមល្បាតជាទៀតទាត់តែងស្ទាក់ចាប់ និងរឹបអូសទប់ស្កាត់សកម្មភាពកាប់ឈើខុសច្បាប់។

**នៅក្នុងឆ្នាំ២០២៣ PFCN និងដៃគូរបស់ខ្លួន PKH បានកត់ត្រាចំនួន ៧៣៤ទិន្នន័យ (រូបភាពទី១០)៖**

## ធនធាន




←រូបភាពទី១១៖
ការឃ្លាំមើលរបស់ PFCN ដោយបានកត់ត្រាទិន្នន័យនៅក្នុងឆ្នាំ២០២៣។ ប្រភេទធនធានផ្សេងៗ។

## បទល្មើស




←រូបភាពទី១២៖
ការឃ្លាំមើលរបស់ PFCN ដោយបានកត់ត្រាទិន្នន័យនៅក្នុងឆ្នាំ២០២៣។ ប្រភេទបទល្មើស។




## ធនធានៈ មានចំនួន

៦២% ស្មើនឹង ៤៥៣ ទិន្នន័យ ដែលទាក់ទងនឹងធនធានផ្សេងៗ។ ដូចដែលបានកត់សម្គាល់នៅក្នុងរបាយការណ៍មុន ប្រភេទឃ្លាំមើលចម្បងសម្រាប់ PFCN គឺដើមច្បោះ ដែលមានចំនួន ២២០ ទិន្នន័យ ដែលមានសារៈសំខាន់សម្រាប់ការរស់រានមានជីវិតរបស់ពួកគេ។ ពួកគេបានកត់ត្រាផងដែរនូវ អនុផលព្រៃឈើមានចំនួន ៧២ ទិន្នន័យ សត្វព្រៃដែលសហគមន៍ជួបប្រទះមានចំនួន ៧១ទិន្នន័យ និងទីតាំងពិសិដ្ឋដ៏មានសារសំខាន់ចំនួន ១៣ ទិន្នន័យ (រូបភាពទី១១)។



↑ រូបភាពទី២១

សេចក្ដីរាយការណ៍ពីដង្កត់ឈើទោលនៅក្នុងដែនជម្រកសត្វព្រៃព្រះរកា ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣

## សកម្មភាពៈ

ប្រភេទនេះមានចំនួន ២៤% នៃទិន្នន័យឃ្លាំមើលនៅក្នុងឆ្នាំ 2023 ស្មើនឹង ១៧៨ ទិន្នន័យ ដែលភាគច្រើនមានចំនួន ៨៧% ទាក់ទងនឹងការកាប់ឈើខុសច្បាប់។ នេះរាប់បញ្ចូលទាំងដង្កត់ឈើប្រណីតទោលមានចំនួន ៨៣ ទិន្នន័យ បន្ទះឈើដែលទុកនៅនឹងកន្លែងមានចំនួន ៣៥ ទិន្នន័យ និងកន្លែងកាប់រានមានចំនួន ២២ ទិន្នន័យ ខណៈដែលការដឹកជញ្ជូនឈើខុសច្បាប់ មិនសូវត្រូវបានរាយការណ៍ញឹកញាប់មានចំនួន ១៦ ទិន្នន័យ (រូបភាពទី១២)។




## ប្រភេទដែលនៅសល់

១៤% នៃទិន្នន័យដែលបានកត់ត្រា ស្ដីពីព្រឹត្តិការណ៍ដែលទាក់ទងនឹងអាកាសធាតុមានចំនួន ៤៩ ទិន្នន័យ ប្រភេទផ្សេងទៀតមានចំនួន ៤១ ទិន្នន័យ និងសេចក្ដីរាយការណ៍ពី អន្តរកម្មវិជ្ជមានជាមួយអាជ្ញាធរមានចំនួន ១៣ ទិន្នន័យ។







## ប្រភេទទូទៅ

← រូបភាពទី១០៖
ការឃ្លាំមើលរបស់ PFCN ដោយបានកត់ត្រាទិន្នន័យនៅក្នុងឆ្នាំ២០២៣។ ប្រភេទសំខាន់ៗ។

# » ការឃ្លាំមើលរបស់សហគមន៍

## សហគមន៍សង្ឃរុក្ខាវ៍ន



# MCF

**↑ រូបភាពទី ២៣**
ព្រៃសង្ឃលែងសត្វពស់មួយក្បាល អំឡុងការចុះល្បាតរបស់ព្រះអង្គ។ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

សហគមន៍សង្ឃរុក្ខាវ៍ន (MCF) ចុះល្បាតដែនជម្រកសត្វព្រៃសង្ឃរុក្ខាវ៍ន ដើម្បីឃ្លាំមើល និងបញ្ឈប់សកម្មភាពខុសច្បាប់ផ្សេងៗ។ ក្នុងនាមជាព្រះសង្ឃដែលជាទីសក្ការៈ នៅក្នុងប្រទេសដែលគោរពព្រះពុទ្ធសាសនាភាគច្រើន សហគមន៍បានជំរុញទំនាក់ទំនងជាវិជ្ជមានជាមួយអាជ្ញាធរមូលដ្ឋាន និងថ្នាក់ខេត្ត។ តាមរយៈទិសដៅក្នុងកិច្ចខិតខំប្រឹងប្រែងការពារបរិស្ថានរបស់ពួកគេ MCF គាំទ្រដោយផ្ទាល់ដល់ប្រជាជនប្រហែល ៤,០០០ នាក់ ដែលពឹងផ្អែកលើព្រៃឈើសម្រាប់របរចិញ្ចឹមជីវិតរបស់ពួកគេ។

**ទោះបីជាការប្រើប្រាស់អែពរបស់ MCF ដើម្បីកត់ត្រាទិន្នន័យតិចជាងបណ្តាញព្រៃឈើផ្សេងទៀតក៏ដោយ ក៏ពួកគេបានគ្រប់គ្រងច្រើនជាងពីរដងនៃទិន្នន័យ ដែលបានកត់ត្រានៅក្នុងឆ្នាំ២០២៣ បើធៀបនឹងឆ្នាំ២០២២ ដោយឈានដល់ចំនួន ៦២ ទិន្នន័យ (រូបភាពទី១៣)។**




**↑ រូបភាពទី១៣៖**
ការឃ្លាំមើលរបស់ MCF ដោយកត់ត្រាទិន្នន័យនៅក្នុងឆ្នាំ២០២៣។ ប្រភេទធនធាន។




## ធនធានៈ

ក្នុងចំណោមទិន្នន័យទាំងនេះមានចំនួន ៧៩% ស្មើនឹង ៤៩ ទិន្នន័យ គឺទាក់ទងទៅនឹងធនធាន (រូបភាពទី១៤)។ ក្នុងនោះរួមមានទិន្នន័យនៃឈើប្រណីត និងដើមច្បោះមានចំនួន ១៩ ទិន្នន័យ សត្វព្រៃមានចំនួន ១៨ ទិន្នន័យ អនុផលព្រៃឈើមានចំនួន ៩ ទិន្នន័យ និងទីតាំងពិសិដ្ឋនៅជុំវិញវត្តអារាមធំៗរបស់ពួកគេមានចំនួន ៣ ទិន្នន័យ។



## សកម្មភាពៈ

នៅសល់ចំនួន ៧ ទិន្នន័យ ពាក់ព័ន្ធទៅនឹងសកម្មភាព រួមមានចំនួន ៤ ទិន្នន័យ ជាដង្គត់ឈើដែលរកឃើញនៅនឹងកន្លែងតំបន់កាប់រាននៅក្នុងប្រភេទការកាប់ឈើខុសច្បាប់មានចំនួន ២ ទិន្នន័យ និងការនេសាទខុសច្បាប់មានចំនួន ១ ទិន្នន័យ។

**←រូបភាពទី២៥**
សេចក្ដីរាយការណ៍ពីដង្គត់ឈើទោលនៅក្នុងដែនជម្រកសត្វព្រៃសង្ឃរុក្ខាវ័ន ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣




## ប្រភេទទូទៅ

**←រូបភាពទី១៣ៈ**
ការឃ្លាំមើលរបស់ MCF ដោយបានកត់ត្រាទិន្នន័យនៅក្នុងឆ្នាំ២០២៣។ ប្រភេទសំខាន់ៗ។

# » ជីវចម្រុះ និងធនធានផ្សេងៗ

**ការទទួលស្គាល់នេះត្រូវបានបង្ហាញឡើងយ៉ាងលេចធ្លោ នៅក្នុង សន្និសីទអនុសញ្ញាអង្គការសហប្រជាជាតិលើកទី១៥ (COP15) ស្តីពីជីវចម្រុះ ដែលបានធ្វើឡើងនៅទីក្រុងម៉ុងរ៉េអាល់ (Montreal) ប្រទេសកាណាដា ក្នុងខែធ្នូ ឆ្នាំ២០២២។ សន្និសីទនេះបានឈានដល់ការអនុម័តក្របខ័ណ្ឌជីវចម្រុះសកល Kunming-Montreal ដែលកំណត់គោលដៅប្រកបដោយមហិច្ឆតា ដើម្បីបញ្ឈប់ លែងឱ្យមានការបាត់បង់ជីវៈចម្រុះនៅឆ្នាំ២០៣០។**

សហគមន៍ និងបណ្តាញជនជាតិដើមភាគតិចដូចជា PLCN PFCN និង MCF ដែលមានចំណេះដឹងជ្រៅជ្រះអំពីប្រព័ន្ធអេកូឡូស៊ីក្នុងមូលដ្ឋានរបស់ពួកគេ ហើយបានអនុវត្តការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានធម្មជាតិជាយូរមកហើយ។ ការស្រាវជ្រាវថ្មីបានគូសបញ្ជាក់ ជាថ្មីម្តងទៀតថា ការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់ដែលត្រូវបានការពារដោយសហគមន៍ជនជាតិដើមភាគតិច គឺមានចំនួនរហូតដល់ ៨៣% តិចជាង បើប្រៀបធៀបទៅនឹងតំបន់ដែលគ្មានការការពារ ។ ការចូលរួមរបស់ពួកគេ គឺមានសារៈសំខាន់សម្រាប់ភាពជោគជ័យនៃគំនិតផ្តួចផ្តើមជីវចម្រុះ ដោយសារពួកគេជាអ្នកមើលការខុសត្រូវ នៅតំបន់ជីវចម្រុះភាគច្រើនបំផុត។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវដូចគ្នានេះក៏បានបង្ហាញផងដែរថា សហគមន៍ជនជាតិដើមភាគតិច មានកម្រិតទាបបំផុតក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ប្រាក់ចំណូលនៅក្នុងដែនដីជនជាតិដើមភាគតិច មានរហូតដល់ ៣៦% តិចជាង បើប្រៀបធៀបទៅនឹងការប្រើប្រាស់ដីនៅកន្លែងផ្សេងទៀត[21]។

ការលើកកម្ពស់សុខុមាលភាពសេដ្ឋកិច្ចរបស់សហគមន៍ជនជាតិដើមភាគតិច មិនត្រឹមតែជាបញ្ហា សម្រាប់យុត្តិធម៌សង្គមប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាយុទ្ធសាស្ត្រដ៏ល្អសម្រាប់បរិស្ថានផងដែរ។ ការស្រាវជ្រាវនៅប្រទេសនេប៉ាល់បានបង្ហាញថា សហគមន៍ដែលមានការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកាន់តែច្រើន មិនសូវមានទំនោរក្នុងកាប់ព្រៃឈើ សម្រាប់ការអភិវឌ្ឍន៍នោះទេ[22]។ ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ទាំងនេះដើម្បីការពារ និងអភិរក្សព្រៃឈើ ក្នុងមូលដ្ឋានរបស់ពួកគេ ខណៈពេលដែលការកែលម្អសុខុមាលភាពសេដ្ឋកិច្ចអាចបង្កើតស្ថានភាពមានអត្ថប្រយោជន៍ទៅវិញទៅមកសម្រាប់ទាំងមនុស្ស និងបរិស្ថាន។

ស្របតាមកិច្ចខិតខំប្រឹងប្រែងជាសាកលទាំងនេះ របាយការណ៍ក្នុងឆ្នាំនេះ ផ្តោតសំខាន់លើជីវៈចម្រុះ។

ការសម្រេចចិត្តនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់យើងក្នុងការយល់ដឹង និងការថែរក្សាភាពសម្បូរបែបនៃជីវសាស្ត្រ ដែលមាននៅក្នុងព្រៃទាំងអស់នេះ។ តាមរយៈការពិនិត្យមើលប្រភេទរុក្ខជាតិដែលត្រូវបានរាយការណ៍ចាប់ពីអាចរុក្ខជាតិដែលអាចបរិភោគបាន ជាឱសថ និងអនុផលព្រៃឈើសម្រាប់សំណង់ (NTFPs) រហូតដល់ដើមឈើប្រណិត និងសត្វព្រៃ យើងមានគោលបំណងគូសបញ្ជាក់ពីទំនាក់ទំនងដ៏ស្មុគស្មាញរវាងកិច្ចខិតខំប្រឹងប្រែងអភិរក្សក្នុងមូលដ្ឋាន និងគោលដៅជីវចម្រុះសកល។ រាល់ព័ត៌មានអំពីការប្រើប្រាស់រុក្ខជាតិ និងដើមឈើ គឺដកស្រង់ចេញពីសៀវភៅ "អំណោយពីធម្មជាតិ" ដែលទើបចេញផ្សាយថ្មីៗ។ វាជាលទ្ធផលនៃការស្រាវជ្រាវជាច្រើនឆ្នាំនៅក្នុងព្រៃឡង់ ដែលបង្ហាញពីចំណេះដឹងរបស់ជនជាតិដើមភាគតិចកួយ និងសហគមន៍ខ្មែរ[23]។

[21] den Braber, B., Oldekop, J.A., Devenish, K. et al. Socio-economic and environmental trade-offs in Amazonian protected areas and Indigenous territories revealed by assessing competing land uses. Nat Ecol Evol (2024). https://doi.org/10.1038/s41559-024-02458-w

[22] Oldekop, J.A., Sims, K.R.E., Karna, B.K. et al. Reductions in deforestation and poverty from decentralized forest management in Nepal. *Nat Sustain* 2, 421- 428 (2019). https://doi.org/10.1038/s41893-019-0277-3

[23] Turreira-Garcia, N. & Argyriou, D. 2023. Gifts from nature: ethnobotanical knowledge of Kuy and Khmer people in Prey Lang Forest. pp. 332. ISBN: 9789924986805

# ធនធានក្រោមអនុផលព្រៃឈើ អាចបរិភោគបាន ដែលត្រូវបាន រាយការណ៍ច្រើនបំផុត

**ផ្អាវ** (*Licuala spinosa Wurmb*) គឺជារុក្ខជាតិដែលមានគល់ជាប់នឹងដី នៃគ្រួសារ Arecaceae ដែលត្រូវបានរកឃើញនៅក្នុងព្រៃល្បោះ ប៉ុន្តែក៏មាននៅក្នុងព្រៃល្បោះបៃតងបបម និងព្រៃពាក់កណ្ដាលបៃតងផងដែរ។ ដើមរបស់វា មានរសជាតិចត់ ប៉ុន្តែវាជួយដល់សុខភាពល្អបំផុត។ បណ្ដូលខ្ចីរបស់វា ត្រូវបានគេយកទៅស្លរជាសម្លម្ជូរ និងធ្វើម្ហូបប្រពៃណីជាច្រើនមុខទៀត។ វាក៏មានផ្លែដែលអាចបរិភោគបានផងដែរ។ ស្លឹកចាស់មានភាពរឹងមាំ ហើយអាចយកទៅវេចខ្ចប់នំអន្សមផ្សេងៗ។




↑ រូបភាពទី២៧
The Paav (ផ្អាវ) *Licuala spinosa Wurmb* shrub

**ទន្សែ** (*Caryota mitis Lour.*), ដែលត្រូវបានគេស្គាល់នៅក្នុងព្រៃឡង់ជា អន្សែ និងចុងអន្សែ។ វាគឺជារុក្ខជាតិដែលមានអាយុវែង នៃគ្រួសារ Arecaceae ដែលត្រូវបានគេរកឃើញនៅក្នុងព្រៃបៃតងបបម ប៉ុន្តែក៏មាននៅក្នុងព្រៃពាក់កណ្ដាលបៃតង និងនៅក្នុងព្រៃល្បោះផងដែរ។ ទន្សែគឺជាប្រភេទរុក្ខជាតិ ដែលគេរាយការណ៍ច្រើនបំផុតពីសហគមន៍នៅក្នុងព្រៃឡង់ ក្នុងប្រភេទអនុផលព្រៃឈើ ដោយបណ្ដូលខ្ចីអាចបរិភោគឆៅជាមួយប្រហុក (ទឹកគ្រឿង) ចំណែកដើមក៏អាចបរិភោគបានដែរ។ សំបករបស់ដើមទន្សែក៏មានលក្ខណៈសម្បត្តិជាឱសថផងដែរ៖ នៅពេលកិនឱ្យម៉ត់ យកទៅលាបលើពោះ ប្រឆាំងនឹងជំងឺគ្រុនក្ដៅ។ ដើមរបស់វាក៏ល្អសម្រាប់ធ្វើបន្ទះរនាប និងត្រូវបានប្រើក្នុងការសាងសង់ផងដែរ។

**ផ្ដៅ** (*Calamus viminalis Willd.*) គឺជារុក្ខជាតិដុះតោង ក្នុងអំបូរ Arecaceae ដែលគេរកឃើញនៅក្នុងព្រៃល្បោះ និងព្រៃបៃតងបបម ប៉ុន្តែមានដុះនៅក្នុងព្រៃពាក់កណ្ដាលបៃតងទាបផងដែរ។ រុក្ខជាតិនេះ គឺជារុក្ខជាតិមួយប្រភេទដែលត្រូវបានគេរាយការណ៍ច្រើនបំផុតនៅក្នុងប្រភេទដែលអាចបរិភោគបាន ដូចជាបណ្ដូលខ្ចី និងផ្លែរបស់វាក៏អាចបរិភោគបានដែរ។ រុក្ខជាតិនេះគឺត្រូវបានប្រើសម្រាប់ធ្វើកន្ត្រក គ្រឿងសង្ហារិម និងផលិតខ្សែសម្រាប់ចង។ វាក៏ប្រើសម្រាប់ជាឱសថផងដែរ។ ឫសរបស់វាប្រើជាថ្នាំសម្រាប់ព្យាបាលជំងឺគ្រុនក្ដៅ (រួមទាំងជំងឺគ្រុនចាញ់) ឈឺក្រពះ និងជួយដល់ស្ត្រីដែលទើបសម្រាលកូនរួច។




→ រូបភាពទី២៨
The Pdao (ផ្ដៅ) *Calamus viminalis Willd.* rattan




← រូបភាពទី២៩
The Tunsae (ទន្សែ) *Caryota mitis* Lour




↑ រូបភាពទី៣០
The Saom (សោម) *Daemonorops jenkinsiana (Griff.) Mart* palm

**សោម** (*Daemonorops jenkinsiana (Griff.) Mart)* គឺជារុក្ខជាតិដែលដុះតោង ក្នុងអំបូរ Arecaceae ដែលគេរកឃើញនៅក្នុងព្រៃវាលភក់ ហើយក៏នៅក្នុងព្រៃបៃតងបបមផងដែរ។ រុក្ខជាតិនេះស្ថិតក្នុងចំណោមរុក្ខជាតិដែលត្រូវបានរាយការណ៍ច្រើនបំផុត នៅក្នុងប្រភេទអនុផលព្រៃឈើដែលអាចបរិភោគបាន ហើយបណ្ដូលខ្ចីរបស់វាគេអាចយកទៅស្លរហូបបាន។ ដើមរបស់រុក្ខជាតិនេះក៏ត្រូវបានគេប្រើជាគ្រឿងសង្ហារិម និងធ្វើកន្ត្រក ខណៈសរសៃត្រូវបានគេប្រើសម្រាប់ធ្វើខ្សែពួរ។ ស្លឹករបស់វាប្រើសម្រាប់ធ្វើដំបូលផ្ទះ និងត្បាញធ្វើជាកម្រាល។

# ធនធានក្រោមអនុផលព្រៃឈើ ដែលប្រើប្រាស់សម្រាប់សិប្បកម្ម ដែលត្រូវបានរាយការណ៍ច្រើនបំផុត



ឆ្វ

→ រូបភាពទី៣១

លក្ខណៈរបស់ដើមឆ្វ (Myrialepis paradoxa (Kurz) J. Dransf) *paradoxa (Kurz)* J. Dransf

**ឆ្វ** (*Myrialepis paradoxa (Kurz) J. Dransf.*) ជារុក្ខជាតិតោង ក្នុងអំបូរ Areacaceae ដែលត្រូវបានគេរកឃើញនៅក្នុងព្រៃល្បោះ ប៉ុន្តែក៏មាននៅក្នុងព្រៃបៃតងបឋមផងដែរ។ រុក្ខជាតិនេះត្រូវបានរាយការណ៍ច្រើនជាងគេក្នុងចំណោមអនុផលព្រៃឈើ ដែលប្រើប្រាស់សម្រាប់សិប្បកម្ម ដោយសារសរសៃពីរល្លិត្រូវបានប្រើដើម្បីធ្វើចង្អេរអុំស្រូវ កន្ត្រក កន្ទេល ខ្សែព្ទរ និងគ្រឿងសង្ហារឹម។ ស្លឹករបស់រុក្ខជាតិនេះប្រើសម្រាប់ធ្វើដំបូលប្រក់។



ស្មាច់

→ រូបភាពទី៣២

ផ្កាស្មាច់ (Syzygium zeylanicum (L.) DC



ជ័រ

↑ រូបភាពទី៣៣

កាដុងដែលដាក់ពេញដោយជ័រច្បោះ

**ស្មាច់** (*Syzygium zeylanicum (L.) DC)* គឺជាប្រភេទដើមឈើក្នុងអំបូរ Myrtaceae ដែលអាចត្រូវបានរកឃើញនៅក្នុងព្រៃល្បោះ និងព្រៃបៃតងបឋម ប៉ុន្តែក៏មាននៅក្នុងព្រៃពាក់កណ្តាលបៃតងទាប និងព្រៃស្រឡៅផងដែរ។ ការស្វែងរកគឺស្ថិតក្នុងចំណោមការរាយការណ៍ច្រើនបំផុតនៅក្នុងប្រភេទសិប្បកម្ម ដោយសារឈើត្រូវបានប្រើសម្រាប់សាងសង់ខ្ទម និងរបង ក៏ដូចជាធ្វើជាអុសដុត។ ការស្វែងរកក៏ស្ថិតក្នុងចំណោមការរាយការណ៍ច្រើនបំផុតនៅក្នុងប្រភេទដែលអាចបរិភោគបាន ដោយស្លឹកខ្ចីអាចបរិភោគឆៅបាន ក៏ដូចជាផ្លែក៏អាចហូបបានដែរ។ លើសពីនេះទៀត វាក៏ត្រូវបានប្រើប្រាស់ជាឱសថផងដែរ។ សំបកអាចដាំទឹកផឹកសម្រាប់ព្យាបាលជំងឺរាគ និងប្រើសម្រាប់ព្យាបាលក្រោយសម្រាល។

**ជ័រច្បោះ** ដែលផលិតពីប្រភេទដើមឈើមួយចំនួន ត្រូវបានចាត់ទុកថាជា អនុផលព្រៃឈើដ៏សំខាន់បំផុតមួយ មិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែនៅទូទាំងអាស៊ីអាគ្នេយ៍។ ជ័រត្រូវបានប្រមូលពី ការចោះផ្នែកតូចមួយរបស់ដើមច្បោះធំៗ រួចយកភ្លើងដុតរណ្តៅដែលចោះរួចនោះ ដើម្បីឱ្យវាចេញជ័រ។ ដោយសារតែកំដៅ ជ័រនឹងហូរចេញមកក្នុងរណ្តៅដែលចោះនោះនៅថ្ងៃបន្ទាប់។ បន្ទាប់មកជ័រត្រូវបានប្រមូល ហើយលក់ទៅឲ្យឈ្មួញដែលមាននៅតាមភូមិនីមួយៗ។ សហគមន៍នៅជាប់ព្រៃជាច្រើនពឹងផ្អែកខ្លាំងលើការទាញយកជ័រទាំងនេះ។



ឈើទាល

↑ រូបភាពទី៣៤

The Chhertheal (ឈើទាល) *Dipterocarpus alatus Roxb. & G.Don* tree

**ឈើទាល** (ឈើទាល) *Dipterocarpus alatus Roxb. & G.Don,* គឺជាដើមឈើមួយប្រភេទ ក្នុងអំបូរ Dipterocarpaceae ហើយជាដើមឈើដែលមានជ័រច្រើនជាងគេ ហើយវាក៏អាចផលិតជ័របានបរិមាណច្រើនបំផុតផងដែរ។ អំបូររុក្ខជាតិប្រភេទនេះជាច្រើនមាននៅក្នុង និងជុំវិញ ដែនជម្រកសត្វព្រៃព្រៃឡង់ និងព្រៃព្រះរកា ដោយអ្នកភូមិពឹកផ្អែកលើជ័ររុក្ខជាតិទាំងនេះ ដើម្បីទ្រទ្រង់ជីវភាពរបស់ពួកគេយ៉ាងសំខាន់ ដែលវាមានសមត្ថភាពបង្កើតប្រាក់ចំណូលពេញមួយឆ្នាំ។ ជ័ររបស់វាក៏ត្រូវបានប្រើប្រាស់ជាពាណិជ្ជកម្មផងដែរ សម្រាប់លាបទូក ធ្វើជាថ្នាំបាញ់ និងថ្នាំលាប ហើយប្រភេទខ្លះត្រូវបានគេប្រើជាគ្រឿងផ្សំនៅក្នុងទឹកអប់។ លើសពីនេះទៀតជ័ររបស់វា ត្រូវបានប្រើក្នុងស្រុក ដោយធ្វើជាចន្លុះដុតបំភ្លឺបានផងដែរ។

# ធនធានក្រោមអនុផលព្រៃឈើដែលប្រើជាឱសថដែលត្រូវបានរាយការណ៍ច្រើនបំផុត

↓ រូបភាពទី៣៥
The Angraedaek (អង្រៃដែក) *Dracaena angustifolia (Medik.) Roxb* treelet




**អង្រៃដែក** (*Dracaena angustifolia (Medik.) Roxb*) គឺជារុក្ខជាតិដែលមានដើមតូចៗ ក្នុងអំបូរ Asparagaceae ត្រូវបានរកឃើញនៅក្នុងព្រៃល្បោះ និងព្រៃបៃតងបឋម។ រុក្ខជាតិនេះត្រូវបានគេរាយការណ៍ច្រើនបំផុតនៅក្នុងប្រភេទអនុផលព្រៃឈើជារុក្ខជាតិឱសថ ព្រោះស្លឹកអាចត្រូវបានគេប្រើប្រាស់ដើម្បីធ្វើឱ្យប្រសើរឡើងនូវសម្ពាធឈាម ដោយគ្រាន់តែដាំទឹកផឹក។ ផ្ការបស់វាអាចដាំជាមួយស្លឹក សម្រាប់ស្ត្រីពិសារក្រោយពេលសម្រាលកូន ដើម្បីបង្កើនប្រព័ន្ធភាពស៊ាំ ជួយឱ្យបាយបាន និងមានទឹកដោះគ្រប់គ្រាន់។ ស្លឹក និងផ្កាខ្ចី ក៏អាចយកមកស្លហូបបានដែរ។




↑ រូបភាពទី៣៦
The Sraomdav (ស្រោមដាវ) *Psychotria asiatica L.* shrub

**ស្រោមដាវ** (*Psychotria asiatica L*) គឺជាដើមឈើមួយប្រភេទ ក្នុងអំបូរ Rutaceae ដែលត្រូវបានរកឃើញនៅក្នុងព្រៃពាក់កណ្ដាលបៃតងទាប។ ឫសរបស់វាត្រូវបានគេត្រាំលាយជាមួយនឹងរុក្ខជាតិឱសថដ៏មានប្រសិទ្ធិភាពផ្សេងទៀត សម្រាប់ផឹកនៅក្រោយសម្រាលកូនរួច ដើម្បីជួយឱ្យបាយបាន និងម្ដាយមានទឹកដោះគ្រប់គ្រាន់។ សំបករបស់វាក៏ត្រូវបានគេប្រើជាគ្រឿងក្រអូបផងដែរ។

**អន្ទង់ស** (*Eurycoma longifolia Jack*) គឺជាប្រភេទរុក្ខជាតិដែលមានដើមតូចៗ ក្នុងអំបូរ Simaroubaceae ដែលត្រូវបានរកឃើញនៅក្នុងព្រៃល្បោះ ព្រៃបៃតងបឋម ព្រៃពាក់កណ្ដាលបៃតងទាប ក៏ដូចជានៅក្នុងព្រៃស្រឡៅដែរ។ វាត្រូវបានគេប្រើជារុក្ខជាតិឱសថ ដែលប្រើប្រាស់ជាឱសថបានជាច្រើនមុខ។ ទាំងសំបក និងសាច់របស់វា ត្រូវបានប្រើប្រាស់ដោយគ្រាន់តែដាក់ត្រាំធម្មតា ហើយផឹកវាដើម្បីព្យាបាលការឈឺឆ្អឹង និងធ្វើឱ្យពិសារបាយបាន។ ឫសរបស់វា អាចយកទៅស្ងោរផឹកជាតែ សម្រាប់ព្យាបាលក្រោយសម្រាលកូនរួច ជាពិសេសជួយព្យាបាលស្បូនលាន់។ សំបករបស់វា ក៏អាចសម្ងួត និងយកធ្វើជាថ្នាំជក់ ដើម្បីព្យាបាលឈាមច្រមុះ ឬជក់ជំនួសបារីក៏បាន។




↑ រូបភាពទី៣៧
The Angtongsor (អន្ទង់ស) *Eurycoma longifolia Jack* treelet.




**ដៃខ្លា** (*Gardenia angkorensis Pit*), គឺជារុក្ខជាតិដែលមានដើមតូចៗ ក្នុងអំបូរ Rubiaceae ដែលត្រូវបានគេរកឃើញនៅក្នុងព្រៃល្បោះ។ សំបកធ្វើជាតែ និងដើមផឹកសម្រាប់ព្យាបាលគ្រុនក្ដៅ។

← រូបភាពទី៣៨
The Daiklar (ដៃខ្លា) *Gardenia angkorensis Pit* treelet.

# ធនធានក្រោមដើមឈើប្រភេទឈើប្រណិត ដែលត្រូវបានរាយការណ៍ច្រើនបំផុត

**ប្រភេទនេះមានដើមឈើដែលត្រូវបានគេស្គាល់ជាចម្បងសម្រាប់ឈើប្រើប្រាស់បានយូរ ជាឈើប្រើសម្រាប់សាងសង់ផ្ទះ។ ជាលទ្ធផល ប្រភេទដើមឈើទាំងនេះត្រូវបានកំណត់គោលដៅដោយអ្នកកាប់ឈើខុសច្បាប់ ហើយភាគច្រើនត្រូវបានចាត់ទុកថា ជាឈើជិតផុតពូជ។**




↑ រូបភាពទី៣៩
The Sralao (ស្រឡៅ) *Lagerstroemia calyculata Kurz* tree

**ស្រឡៅ** (*Lagerstroemia calyculata Kurz*) ជាដើមឈើមួយប្រភេទនៅក្នុងអំបូរ Lythraceae ហើយដុះនៅក្បែរៗគ្នាយ៉ាងក្រាស់ ដែលកំណត់ជាឈ្មោះប្រភេទព្រៃជាក់លាក់មួយគឺ ព្រៃស្រឡៅ។ ដូច្នេះវាគឺជាប្រភេទរុក្ខជាតិដែលត្រូវបានរាយការណ៍ច្រើនបំផុតនៅក្នុងប្រភេទនេះ។ សាច់របស់វារឹង និងធ្ងន់ ហើយប្រើជាឈើសាងសង់ផ្ទះ ប៉ុន្តែក៏ល្អសម្រាប់អុសផងដែរ។ ដើមរបស់វាមានលក្ខណៈសម្បត្តិសម្រាប់ព្យាបាលផងដែរ។ សំបកធ្វើជាតែ ផឹកសម្រាប់ព្យាបាលរាគ។ ជ័រអាចលាបលើមុខរបួសដើម្បីជួយព្យាបាល។ ស្លឹកខ្ចីក៏អាចបរិភោគឆៅបានដែរ។

**ផ្ដៀក** (*Anisoptera costata Korth*) គឺជាដើមឈើខ្ពស់មួយប្រភេទក្នុងអំបូរ Dipterocarpaceae ដែលត្រូវបានរកឃើញនៅក្នុងព្រៃបៃតងបឋម និងព្រៃពាក់កណ្ដាលបៃតងទាប។ សាច់ឈើត្រូវបានគេប្រើសម្រាប់សាងសង់ផ្ទះ បង្គោល និងបន្ទះក្ដារ។ វាធន់នឹងពពួកសត្វល្អិត ប៉ុន្តែងាយនឹងដុះផ្សិត និងខ្ទួតស៊ី។

**ចំបក់** (*Irvingia malayana Oliv. ex A.W.Benn*) គឺជាដើមឈើមួយប្រភេទ នៃគ្រួសារ Irvingiaceae ដែលត្រូវបានរកឃើញនៅក្នុងព្រៃបៃតងបឋម ប៉ុន្តែក៏មាននៅក្នុងព្រៃពាក់កណ្ដាលបៃតងទាប និងនៅក្នុងព្រៃស្រឡៅផងដែរ។ សាច់ឈើរឹងណាស់ ប៉ុន្តែមិនធន់នឹងសត្វល្អិត។ វាត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់ទូទៅ និងធ្វើជាប្រេង និងធ្វើជាធ្យូងដ៏ល្អឥតខ្ចោះ។ ដើមឈើនេះក៏មានគុណសម្បត្តិជាឱសថផងដែរ ព្រោះសំបកអាចដាក់ត្រាំក្នុងទឹកត្រជាក់ដើម្បីព្យាបាលគ្រុនក្ដៅ។ សំបករបស់វាអាចធ្វើជាតែ និងសាច់ឈើអាចដាំផឹកសម្រាប់ព្យាបាលរោគសើស្បែក និងហើមដៃជើង។ ផ្លែរបស់វាក៏អាចបរិភោគបានដែរ។



ចំបក់

→ រូបភាពទី៤១
(ចំបក់) *Irvingia malayana Oliv. ex A.W.Benn* tree

↓ រូបភាពទី៤០
The Pdeak (ផ្ដៀក) *Anisoptera costata Korth* tree.

ផ្ដៀក





## កកោះ

**កកោះ** *(Sindora siamensis Miq.)* គឺជាដើមឈើមួយប្រភេទនៃគ្រួសារ Fabaceae ដែលអាចត្រូវបានរកឃើញនៅក្នុងព្រៃបៃតងបឋម ព្រៃពាក់កណ្ដាលបៃតងទាប និងព្រៃស្រឡៅ។ សាច់ឈើមានភាពរឹងមាំ និងប្រើប្រាស់បានយូរ ធន់នឹងការវាយប្រហារពីសត្វល្អិត និងងាយស្រួលក្នុងការកែច្នៃ។ វាល្អសម្រាប់ធ្វើបន្ទះក្ដារ បង្គោលសំណង់ គ្រឿងដំបូល គ្រឿងសង្ហារិម និងទូក។ សំបកក៏អាចត្រូវបានបន្ថែមរសជាតិទៅក្នុងស្រាអង្គរ។ វាក៏មានផ្លែដែលអាចបរិភោគបានដែរ។

↑ រូបភាពទី៤២
The Korkoh (កកាះ) *Sindora siamensis Miq* tree.



## ខ្នុរព្រៃ

**ខ្នុរព្រៃ** *(Artocarpus chama Buch.–Ham)* ជាដើមឈើមួយប្រភេទនៃគ្រួសារ Moraceae ដែលមាននៅក្នុងព្រៃបៃតងបឋម និងក្នុងព្រៃស្រឡៅ។ សាច់ឈើត្រូវបានគេប្រើសម្រាប់ការសាងសង់ផ្ទះក្នុងទម្រង់ជាបង្គោល និងបន្ទះឈើ និងសម្រាប់គ្រឿងសង្ហារិមផងដែរ។ សំបក និងសាច់របស់វាហាន់ជាដុំតូចៗ ស្ងោរជាតែសម្រាប់ផឹក ឬដាក់ក្នុងទឹកត្រជាក់ រួចងូតទឹកដើម្បីព្យាបាលការឆ្លងរោគ និងកន្ទួលលើស្បែក។ ផ្លែរបស់វាអាចបរិភោគបាន។

↑ រូបភាពទី៤៣
The fruit of Knorprey (ខ្នុរព្រៃ) *Artocarpus chama Buch.*–Ham



## ផ្ចឹក

**ផ្ចឹក** *(Shorea obtusa Wall. ex Bl.)* គឺជាដើមឈើជិតទទួលរងការគំរាមកំហែង នៃគ្រួសារ Dipterocarpaceae ដែលត្រូវបានរកឃើញនៅក្នុងព្រៃល្បោះ។ សាច់ឈើល្អសម្រាប់សាងសង់ផ្ទះ បង្គោល និងបន្ទះក្ដារ។ សំបករបស់វា ត្រូវគេយកមកធ្វើជាថ្នាំព្យាបាលផ្សំជាមួយសំបកឈើផ្សេងៗ ដើម្បីកាត់បន្ថយស្នាមជាំលើរាងកាយ។

← រូបភាពទី៤៥
Leaves of Pchek (ផ្ចឹក) *Shorea obtusa Wall. ex* Bl.



## ត្រាច

**ត្រាច** (*Dipterocarpus intricatus Dyer.*) ជាប្រភេទដើមឈើខ្ពស់ជិតផុតពូជ នៃគ្រួសារ Dipterocarpaceae ដែលអាចរកបាននៅតាមព្រៃល្បោះ ព្រៃបៃតងបឋម ព្រៃពាក់កណ្ដាលបៃតង និងព្រៃស្រឡៅផងដែរ។ ដូចជាប្រភេទឈើមុនៗទាំងអស់ សាច់ឈើត្រូវបានគេប្រើជាឈើសំណង់ ប៉ុន្តែក៏អាចទាញយកជ័ររបស់វាបានដែរ។ លើសពីនេះ វាក៏មានលក្ខណៈសម្បត្តិជាឱសថផងដែរ៖ តែធ្វើពីសំបកអាចព្យាបាលជំងឺក្អកធ្លាក់ឈាម។ តែពីសំបកឈើដើម្បីព្យាបាលការក្អកបង្ហូរឈាម ហើយទឹកពីដើមអាចផឹកដើម្បីព្យាបាលរាគ និងប៉ារ៉ាស៊ីត។

←រូបភាពទី៤៤
The Trach (ត្រាច) *Dipterocarpus intricatus Dyer* tree

## ពពេល

**Porpael** (ពពេល) *Shorea roxburghii G. Don* គឺជាប្រភេទដើមឈើនៅក្រោមគ្រួសារ Dipterocarpaceae family ដែលត្រូវបានរកឃើញនៅក្នុងព្រៃបៃតងបឋម ព្រៃរបោះ និងព្រៃស្រឡៅ។ ឈើនេះត្រូវបានគេប្រើសម្រាប់ការសាងសង់ទូក និងផ្ទះបង្គោល និងក្ដារ។ សំបកឈើត្រូវបានត្រាំ នៅក្នុងទឹកត្នោត ដើម្បីធ្វើឱ្យភេសជ្ជៈផ្អែម។



រូបភាពទី៤៦
The Porpael (ពពេល) *Shorea roxburghii G. Don* tree

# សេចក្ដីរាយការណ៍ ភាគច្រើនក្រោម ប្រភេទសត្វព្រៃ




↑ រូបភាពទី៤៧
ដានជើងជ្រូកព្រៃ (Sus scrofa) ត្រូវបានប្រទះឃើញនៅក្នុងខេត្តក្រចេះ ថ្ងៃទី២១ តុលា ឆ្នាំ២០២៣

**ជ្រូកព្រៃ** *(Sus scrofa)* អាចត្រូវបានរកឃើញនៅតាមទីជម្រកផ្សេងៗ រួមទាំងក្នុងព្រៃ និងតំបន់កសិកម្មផ្សេងៗ។ ពួកវាជាប្រភេទសត្វដែលត្រូវបានគេរាយការណ៍ច្រើនជាងគេបំផុត ដោយសហគមន៍ នៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ ព្រៃព្រះរកា និងសង្ឃរុក្ខាវ័ន។ ជ្រូកព្រៃដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធអេកូឡូស៊ី ដោយការឈ្មុសដី សម្រួលដល់ជីវិតរុក្ខជាតិ និងបំបែកគ្រាប់ពូជផ្សេងៗ។ ជំងឺដូចជា ប៉េស្តជ្រូកអាហ្វ្រិកបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើចំនួនជ្រូកព្រៃនៅក្នុងប្រទេសកម្ពុជា ដែលបង្កហានិភ័យយ៉ាងធ្ងន់ធ្ងរដល់ចំនួនរបស់ពួកវា[24]។ ចំនួនរបស់ពួកគេបានធ្លាក់ចុះ ១៨% ក្នុងរយៈពេល ២០១០-២០២០ នេះបើយោងតាមការសិក្សាថ្មីមួយពីក្រសួងបរិស្ថាន និងអង្គការមូលនិធិសកលសម្រាប់អភិរក្សធម្មជាតិ(WWF)[25]។ ពួកវាក៏ត្រូវបានវាយប្រហារដោយសត្វធំៗ ដូចជាខ្លារខិន ដែលតាមការសិក្សាកំពុងឈានដល់ជិតផុតពូជ[26]។




→ រូបភាពទី៤៨
ដានជើងសត្វឈ្លូស (Muntiacus muntjac) ត្រូវបានប្រទះឃើញនៅក្នុងខេត្តក្រចេះ នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៤




↑ រូបភាពទី៤៩
ដានជើសសត្វប្រើស (Cervus unicolour) ត្រូវបានប្រទះឃើញនៅក្នុងខេត្តស្ទឹងត្រែង នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២

**ប្រើស** *(Cervus unicolour)*, គឺជាប្រភេទសត្វប្រើសធំមួយ មានដើមកំណើតនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដែលអាចត្រូវបានរកឃើញនៅក្នុងព្រៃស្រោង វាលស្មៅ និងនៅជិតប្រភពទឹកផ្សេងៗ[27]។ វាស្រដៀងទៅនឹងសត្វឈ្លូស (*Muntiacus muntjac)*, ដែលតូចជាង ហើយជាសត្វមួយក្នុងចំណោមសត្វផ្សេងទៀតដែលត្រូវបានគេរាយការណ៍ច្រើនបំផុតនៅក្នុងដែនជម្រកសត្វព្រៃព្រះរកា។ ពួកវាចូលចិត្តជម្រកដែលមានរុក្ខជាតិក្រាស់ ដើម្បីជួយបាំងបិតពួកវាពីសត្វស៊ីសាច់ជាអាហារ។ ប្រភេទសត្វស៊ីស្មៅទាំងពីរនេះ ត្រូវបានគេស្គាល់ថាជាសត្វរស់នៅទោល ឬជាក្រុមតូចៗ ។ ពួកវាជាសត្វរាត្រីចរ សត្វដែលសកម្មបំផុតនៅពេលយប់ ហើយត្រូវបានតាមប្រមាញ់ដោយសត្វស៊ីសាច់ជាអាហារធំៗ ដូចជាខ្លាធំ និងខ្លារខិន។ ប្រើសត្រូវបានគេស្គាល់ផងដែរថាជា "សត្វក្ដាន់" ដែលជាឈ្មោះមួយកើតចេញពីទំនោររបស់ពួកគេក្នុងការស្រែកយំនៅពេលដែលពួកគេដឹងពីការគំរាមកំហែងនៅក្បែរខ្លួន ដោយបញ្ចេញសម្លេងស្រែកហៅ "ដូចឆ្កែ" ក្នុងការព្យាយាមដើម្បីបន្លាចសត្វស៊ីសាច់ជាអាហារ។ យោងតាមការសិក្សាខាងលើ ចំនួនសត្វប្រើស ក្នុងប្រទេសកម្ពុជាបានថយចុះជាង ៥០% ក្នុងរយៈពេលមួយទសវត្សរ៍ពីឆ្នាំ២០១០-២០២០[25]។

**ដំរីអាស៊ី** *(Elephas maximus)*, រស់នៅក្នុងបរិយាកាសផ្សេងៗគ្នា រួមទាំងព្រៃបៃតងត្រូពិច ព្រៃពាក់កណ្ដាលបៃតង និងវាលស្មៅ[29]។ ពួកវាជាសត្វដែលរស់នៅលើផ្ទៃដីដែលមានទំហំធំជាងគេនៅអាស៊ី។ ពួកវាមានលក្ខណៈពិសេសប្លែក ដោយមានប្រមោយវែង និងត្រចៀកធំ ហើយដំរីឈ្មោលជាធម្មតាមានភ្លុក។ ពួកគេអាចមានទម្ងន់រហូតដល់ ៤ តោន និងអាចឈរបានកម្ពស់ ២.៧ ម៉ែត្រនៅត្រង់ស្មា។ សត្វស៊ីរុក្ខជាតិទាំងនេះអាចស៊ីស្លឹករុក្ខជាតិរហូតដល់ ១៥០ គីឡូក្រាម ដោយចំណាយពេលស៊ីអស់រយៈពេល ២០ ម៉ោងក្នុងមួយថ្ងៃ[30]។




← រូបភាពទី៥០
ដានជើងសត្វដំរីអាស៊ី (Elephas maximus) ត្រូវបានប្រទះឃើញនៅក្នុងខេត្តក្រចេះ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៣

**ទន្សោង** (*Bos javanicus),* ត្រូវបានគេរកឃើញនៅតាមទីជម្រកផ្សេងៗ រួមទាំងព្រៃរបោះបើកទូលាយ ព្រៃពាក់កណ្ដាលបៃតង និងវាលស្មៅ។ ទន្សោងមានភិនភាគស្រដៀងនឹងគោក្របីអ្នកស្រុកដែរ ដែលមានកម្ពស់ដល់ទៅ ១,៦៥ ម៉ែត្រ និងទម្ងន់រហូតដល់ ៨០០ គីឡូក្រាម។ សត្វពាហនៈទាំងនេះត្រូវបានចាត់ថ្នាក់ថា ជាសត្វជិតផុតពូជនៅក្នុងបញ្ជីក្រហមរបស់ IUCN។ ចំនួនរបស់ពួកគេបានធ្លាក់ចុះជាង ៧០% ក្នុងរយៈពេលពី ២០១០-២០២០ នេះបើយោងតាមការសិក្សាដែលរៀបរាប់ខាងលើរបស់ក្រសួងបរិស្ថាន និងអង្គការមូលនិធិសកលសម្រាប់អភិរក្សធម្មជាតិ(WWF)[25]។




**←រូបភាពទី៥១**
ដានជើងសត្វទន្សោង (Bos javanicus) ត្រូវបានប្រទះឃើញនៅក្នុងខេត្តព្រះវិហារ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣

**ស្វាក្ដាម** (*Macaca fascicularis*), គឺជាប្រភេទសត្វ ដែលត្រូវបានគេរាយការណ៍ច្រើនបំផុតក្នុងដែនជម្រកសត្វព្រៃទាំងបី។ ពួកវាត្រូវបានរកឃើញនៅតាមទីជម្រកផ្សេងៗ រួមទាំងព្រៃឈើ ព្រៃកោងកាង និងសូម្បីតែតំបន់ទីក្រុង។ សត្វដែលស៊ីរុក្ខជាតិ និងសត្វផ្សេងៗ ទាំងនេះ អាចសម្របខ្លួនបានខ្ពស់ ហើយអាចធំធាត់ក្នុងបរិយាកាសចម្រុះ[31]។ សត្វស្វាក្ដាមទាំងនេះត្រូវបានគេស្គាល់ ដោយសារវាមានកន្ទុយដ៏វែង ដែលជារឿយៗវែងជាងរាងកាយរបស់វា។ ពួកវាមានសម្បុរពណ៌ត្នោតប្រផេះ និងផ្នែកខាងក្រោមពណ៌ស្រាលជាង ហើយពួកគេត្រូវបានដឹងថា មានភាពឆ្លាតវៃ ដូចដែលពួកវា ចេះប្រើប្រាស់ឧបករណ៍អ្វីមួយដើម្បីទទួលបានអាហារ។




**↑រូបភាពទី៥២**
ដានជើងសត្វស្វាក្ដាម (Macaca fascicularis) ត្រូវបានប្រទះឃើញនៅក្នុងខេត្តក្រចេះ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣

## នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២ មន្ត្រីជំនាញសត្វព្រៃកម្ពុជាមួយចំនួន និងសមាជិកនៃក្រុមហ៊ុនផ្គត់ផ្គង់សត្វព្រៃ Vanny Resources Holdings ត្រូវបានចោទប្រកាន់ពីបទនាំចេញសត្វស្វាដែលជិតផុតពូជទាំងនេះដោយខុសច្បាប់។

នាយកប្រតិបត្តិកំពូលនៃក្រុមហ៊ុនដែលមានមូលដ្ឋាននៅទីក្រុងហុងកុងបានធ្វើការជាមួយឈ្មួញទីផ្សារងងឹត និងមន្ត្រីក្នុងប្រទេសកម្ពុជា ដែលក្នុងនោះមានលោក កែវ អូម៉ាលីស អគ្គនាយករដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទកម្ពុជា។ គម្រោងនេះទទួលបានសត្វស្វាដែលចាប់បានពីក្នុងព្រៃ ហើយបានបំប្លែងនៅកន្លែងបង្កាត់ពូជរបស់កម្ពុជា ដើម្បីលាក់បាំងថា ពួកវាត្រូវបានគេយកចេញពីឧទ្យានជាតិ និងតំបន់ការពារ នេះបើយោងតាមការចោទប្រកាន់[32]។ ជនសង្ស័យដ៏សំខាន់ គឺលោក គ្រី ម៉ះផល នាយកផ្នែកសត្វព្រៃ និងជីវចម្រុះ រដ្ឋបាលព្រៃឈើកម្ពុជា ត្រូវបានឃុំខ្លួនតាំងពីពេលនោះមក ប៉ុន្តែទីបំផុតត្រូវបានតុលាការសហរដ្ឋអាមេរិកដោះលែងឲ្យមានសេរីភាពវិញក្នុងខែមីនា ឆ្នាំ២០២៤ ទោះបីជាមានភស្តុតាងគ្រប់គ្រាន់ក៏ដោយ[33]។ សេចក្តីថ្លែងការណ៍របស់ក្រសួងបន្ទាប់ពីការចេញផ្សាយរបស់លោក ម៉ះផល បានកត់សម្គាល់ថា ករណីនេះ "គ្មានភស្តុតាង" ទោះបីជាគាត់ត្រូវបានគេចាប់បានភស្តុតាងនៅលើវីដេអូមួយ[34] ដែលបង្ហាញពីការជាប់ពាក់ព័ន្ធរបស់គាត់។ ក្រុមមនុស្សដើម្បីការប្រព្រឹត្តប្រកបដោយអភិសមាចារលើសត្វ (PETA) បានចេញសេចក្តីថ្លែងការណ៍មួយដែលសរសេរថា "ទោះជាសាលក្រមបែបណាក៏ដោយ ភស្តុតាងបង្ហាញថាសត្វស្វារាប់មិនអស់ ត្រូវបានចាប់ពង្រត់ចេញពីព្រៃជម្រករបស់ពួកគេ ហើយបំប្លែងទៅជាស្របច្បាប់"[35]។ សត្វស្វាក្ដាម ត្រូវបានចុះក្នុងបញ្ជីក្រហមជាសត្វជិតផុតពូជរបស់ IUCN[36]។

[24] African swine fever (ASF) situation update in Asia & Pacific - Food and Agriculture Organization of the United Nations, 5 September 2024

[25] Urgent action needed to protect ungulate species as their populations dwindled over the past decade - WWF Cambodia, 15 January 2021

[26] New Study Confirms Cambodia□s Last Leopards on Brink of Extinction - Panthera, 1 March 2018

[27] Sambar - Water-loving Deer of Southeast Asia - The website of Everything

[28] Muntjac (Muntiacus muntjak) - Murray Thomas, 11 Septemebr 2019

[29] Cambodian Elephants - Mondulkiri project, 7 April 2018

[30] Indian Elephant - Jungle Dragon

[31] Long-Tailed Macaque - New England Primate Conservancy

[32] Justice Department charges 8 in alleged international monkey smuggling ring - NBC News, 16 November 2022

[33] Cambodian official acquitted in trial that exposed monkey-laundering scheme - Mongabay 29 March 2024

[34] Former Cambodian official caught on video involved in monkey smuggling case - Radio Free Asia (RFA), 6 May 2023

[35] Despite Acquittal, Smuggling Trial Offered Glimpse Into Corrupt and Cruel Business of Monkey Importation - PETA 8 March 2024

[36] Long-Tailed Macaque - Bali Wildlife

**ខ្លាឃ្មុំធំ** *(Ursus thibetanus)*, គឺជាប្រភេទខ្លាឃ្មុំខ្នាតមធ្យមដែលមានដើមកំណើតនៅអាស៊ី។ ពួកវាត្រូវបានរកឃើញនៅតាមទីជម្រកផ្សេងៗ រួមមានទាំងតំបន់ព្រៃ និងតំបន់ភ្នំ។ ខ្លាឃ្មុំទាំងនេះត្រូវបានគេសម្គាល់ថា មានស្នាមទ្រូងពណ៌សខុសប្លែកពីគេ ដែលច្រើនតែស្រដៀងនឹងអឌ្ឍចន្ទ ហេតុនេះហើយបានគេដាក់រហស្សនាមថា "ខ្លាឃ្មុំព្រះច័ន្ទ (moon bear)"។ ពួកវាមានសម្បុរពណ៌ខ្មៅ ហើយអាចមានទម្ងន់ចាប់ពី៦០ ទៅ២០០ គីឡូក្រាម ។ ពួកវាជាសត្វពាហនៈ ហើយត្រូវបានគេស្គាល់ផងដែរក្នុងការលួចឆ្ក់ដំណាំ ដែលជួនកាលនាំឱ្យពួកវាពើបប្រទះនឹងមនុស្ស[37]។ ចំនួនរបស់ពួកវាកំពុងធ្លាក់ចុះនៅទូទាំងតណ្ឌចិន ហើយត្រូវបានចុះបញ្ជីថា ជាប្រភេទសត្វងាយរងគ្រោះ ក្នុងបញ្ជីក្រហមរបស់ IUCN[38]។




→ **រូបភាពទី៥៣**
ដានជើសសត្វខ្លាឃ្មុំធំ (Ursus thibetanus) ត្រូវបានប្រទះឃើញនៅក្នុងខេត្តក្រចេះ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤




↑ **រូបភាពទី៥៤**
ដានជើងសត្វសំពោចក្រអូប ឬសំពោចត្នោត (Paradoxurus hermaphroditus) ត្រូវបានប្រទះឃើញនៅក្នុងខេត្តក្រចេះ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣

**សំពោចក្រអូប ឬសំពោចត្នោត** *(Paradoxurus hermaphroditus)*, គឺជាថនិកសត្វតូចមួយដែលមានដើមកំណើតនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍។ ពួកវាអាចសម្របខ្លួនបានខ្ពស់ ហើយអាចត្រូវបានរកឃើញនៅក្នុងទីជម្រកជាច្រើន រួមទាំងព្រៃឈើបឋម ព្រៃឈើបន្ទាប់បន្សំចម្ការ និងសូម្បីតែនៅតំបន់ទីក្រុង។ ពួកវាសកម្មនៅពេលយប់ និងចំណាយពេលភាគច្រើនរបស់វារស់នៅលើដើមឈើ។ ពួកវាជាសត្វទោលដែលមករស់នៅជុំគ្នាតែក្នុងអំឡុងពេលបន្តពូជប៉ុណ្ណោះ[39]។ សត្វដែលស៊ីរុក្ខជាតិ និងសត្វផ្សេងៗទាំងនេះ ត្រូវបានដឹងថា បានតួនាទីក្នុងការផលិតកាហ្វេ kopi luwak ដែលជាប្រភេទកាហ្វេដែលផលិតចេញពីសណ្តែក ដែលត្រូវបានស៊ី និងបញ្ចេញចោលតាមលាមកដោយសត្វ។ អង់ស៊ីមរំលាយអាហាររបស់សត្វសំពោច ត្រូវបានគេជឿថាអាចផ្លាស់ប្តូរសមាសធាតុគីមីរបស់សណ្តែក ដែលបណ្តាលឱ្យមានទម្រង់រសជាតិប្លែក។ ទោះជាយ៉ាងណាក៏ដោយ ការផលិតកាហ្វេ kopi Luwak បានបង្កើនការព្រួយបារម្ភអំពីក្រមសីលធម៌ជាខ្លាំង។ មានសត្វសំពោចជាច្រើនត្រូវបានរក្សាទុកនៅក្នុងលក្ខខណ្ឌអាក្រក់ ដែលអាចនាំឱ្យមានបញ្ហាសុខភាព និងអត្រាងាប់ខ្ពស់[40]។ ពួកគេត្រូវបានចុះបញ្ជីថា មានការព្រួយបារម្ភតិចតួចបំផុត ក្នុងបញ្ជីក្រហមរបស់ IUCN ដោយសារតែការចែកចាយដ៏ធំទូលាយ និងមានចំនួនច្រើន។

**ប្រភេទសត្វព្រៃទាំងអស់ដែលបានរៀបរាប់ខាងលើ ប្រឈមនឹងការគំរាមកំហែងដូចគ្នា ដែលកំពុងបង្កគ្រោះថ្នាក់ដល់ការរស់រានមានជីវិតរបស់ពួកវា។ បញ្ហាប្រឈមចម្បងមួយ គឺការបាត់បង់ទីជម្រក និងការបែកខ្ញែកគ្នា[30,41,42,43]។ បញ្ហានេះភាគច្រើនត្រូវបានកើតឡើងដោយសារកំណើនតម្រូវការរបស់មនុស្សសម្រាប់ការប្រើប្រាស់ឈើប្រណីត ដែលនាំទៅដល់ការកាប់បំផ្លាញព្រៃឈើ និងការរិចរិលព្រៃឈើយ៉ាងខ្លាំងខ្លា។ ការដកយកឈើខុសច្បាប់ គឺជាបញ្ហាមួយដែលត្រូវបានគេមើលឃើញនៅក្នុងដែនជម្រកសត្វព្រៃទាំងបី ហើយធ្វើឱ្យបញ្ហានេះកាន់តែធ្ងន់ធ្ងរឡើងបន្ថែមទៀត ។**

ដែលរួមចំណែកយ៉ាងសំខាន់ដល់ការរិចរិលនូវជម្រកធម្មជាតិ។ លើសពីនេះ ការពង្រីកវិស័យកសិកម្ម និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដីសេដ្ឋកិច្ច និងសម្បទានរុករករ៉ែ បានរំលោភបំពានលើតំបន់ព្រៃឈើ ដោយកាត់បន្ថយទំហំដែលមានសម្រាប់សត្វព្រៃដើម្បីរស់នៅ។ នៅពេលដែលទីជម្រករបស់ពួកវាថយចុះ សត្វទាំងនេះត្រូវបានបង្ខំឱ្យចូលទៅជិតជាមួយនឹងការតាំងទីលំនៅរបស់មនុស្ស ដែលនាំឱ្យមានការពើបប្រទះគ្នា ជាមួយនឹងមនុស្សកើនឡើង។ ជាឧទាហរណ៍ សត្វដំរីអាចវាយឆ្មក់ដំណាំ ហើយសត្វស្វា ខ្លាឃ្មុំ និងសំពោចអាចចូលទៅក្នុងភូមិ ដែលបណ្តាលឱ្យមានគ្រោះថ្នាក់។

ការបរបាញ់ និងការប្រមាញ់ ក៏បង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ប្រភេទសត្វទាំងនេះផងដែរ។ សត្វជាច្រើនត្រូវបានបរបាញ់សម្រាប់សាច់ និងស្នែងរបស់ពួកគេ ខណៈដែលសត្វខ្លះទៀតត្រូវបានកំណត់គោលដៅសម្រាប់យកផ្នែកខ្លះនៃរាងកាយរបស់ពួកគេ ដែលត្រូវបានគេប្រើប្រាស់ជាឱសថបុរាណ[24,38]។ ពាណិជ្ជកម្មសត្វចិញ្ចឹម និងឧស្សាហកម្មស្រាវជ្រាវជីវវេជ្ជសាស្ត្រក៏ជំរុញឱ្យមានការចាប់យកប្រភេទសត្វដូចជា សត្វស្វាកន្ទុយវែង និងសំពោចត្នោតផងដែរ។ ការជួញដូរសត្វព្រៃខុសច្បាប់នេះ មិនត្រឹមតែកាត់បន្ថយចំនួនរបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរំខានដល់តុល្យភាពអេកូឡូស៊ីផងដែរ។ លើសពីនេះទៅទៀត ការរីករាលដាលនូវការប្រើប្រាស់អន្ទាក់ដើម្បីចាប់សត្វព្រៃ ដើម្បីជួញដូរខុសច្បាប់ បានបង្កើតនូវវិបត្តិមួយ ដែលធ្វើឱ្យសត្វទាំងនេះមានគ្រោះថ្នាក់ថែមទៀត។

**ផលប៉ះពាល់ជាច្រើន រួមមានការបាត់បង់ទីជម្រក ការបរបាញ់ ការប្រមាញ់ និងការពើបប្រទះជាមួយមនុស្ស បាននាំឱ្យមានការថយចុះគួរឱ្យកត់សម្គាល់នូវចំនួនសត្វព្រៃនៅទូទាំងប្រទេសកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងអភិរក្សមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហាទាំងនេះ និងការពារជីវចម្រុះដ៏សម្បូរបែបរបស់ប្រទេស។**



**អន្ទាក់**

**↑ រូបភាពទី៥៥**
អន្ទាក់ត្រូវបានរាយការណ៍នៅក្នុងដែនជម្រកសត្វព្រៃព្រះរកា

[37] Asiatic Black Bear - WWF Cambodia

[38] McCann G., Pawlowski K., Sinovas P., Thon S. Asiatic black bears and sun bears in Virachey National Park, Northeast Cambodia, Ursus, 2022(33e15), 1-9, (21 December 2022) https://doi.org/10.2192/URSUS-D-21-00022.1

[39] Asian Palm Civet - Animal Diversity Web

[40] Exotic Coffee Brew from Park's Civet Cousins - Cambodianess, 16 November 2023

[41] Muntjac Deer 101 - Deer Donkey

[42] Southeast Asian wild pigs confront deadly African swine fever epidemic - Mongabay 12 February 2021

[43] First Confirmation of Endangered Banteng in Cambodia's Cardamom Mountains - Wild Earth allies, 1 May 2024

# » ការផ្សារភ្ជាប់ការរកឃើញនៅមូលដ្ឋាន ទៅនឹងក្របខ័ណ្ឌជីវចម្រុះសកល

**កិច្ចព្រមព្រៀង ក្របខណ្ឌជីវចម្រុះសាកល (GBF) Kunming-Montreal ដែលធ្វើឡើងនៅ COP១៥ តំណាងឱ្យពេលវេលាដ៏សំខាន់មួយនៅក្នុងអភិបាលកិច្ចបរិស្ថានពិភពលោក។ ក្របខណ្ឌនេះមានគោលបំណងបញ្ឈប់ និងស្តារ ការបាត់បង់ជីវចម្រុះនៅឆ្នាំ២០៣០ ដោយកំណត់គោលដៅប្រកបដោយមហិច្ឆតាដែលដោះស្រាយបញ្ហាឫសគល់នៃការថយចុះនូវជីវចម្រុះ។**

សារៈសំខាន់នៃ GBF COP១៥ ស្ថិតនៅក្នុងវិធីសាស្ត្រដ៏ទូលំទូលាយ ដែលរួមបញ្ចូលការអភិរក្ស ការប្រើប្រាស់ប្រកបដោយចីរភាព និងការចែករំលែកអត្ថប្រយោជន៍ប្រកបដោយសមធម៌។ តាមរយៈការជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ និងសង្កត់ធ្ងន់លើតួនាទីរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន GBF ស្វែងរកការបង្កើតអនាគតប្រកបដោយនិរន្តរភាព ដែលជីវៈចម្រុះលូតលាស់ ប្រព័ន្ធអេកូមានភាពល្អដូចដើមឡើងវិញ និងសុខុមាលភាពរបស់មនុស្សត្រូវបានពង្រឹង។ គោលដៅរយៈពេលវែងទាំងបួន និងគោលដៅរយៈពេលខ្លីទាំង ២៣ ដែលបានព្រមព្រៀងក្នុងក្របខ័ណ្ឌនេះ បង្កើតជាផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការរួមរស់ជាមួយគ្នាប្រកបដោយសុខដុមរមនាជាមួយធម្មជាតិ ដោយធានាថាអត្ថប្រយោជន៍ដែលទទួលបានពីជីវចម្រុះ ត្រូវបានមនុស្សគ្រប់រូបពេញចិត្ត។ ដោយចងចាំរឿងនេះ ផ្នែកខាងក្រោមស្វែងយល់ពីរបៀបដែលកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍មានសារៈសំខាន់ចំពោះផែនទីបង្ហាញផ្លូវនេះឆ្ពោះទៅរកនិរន្តរភាព។



↑ រូបភាពទី៥៦
សហគមន៍ខេត្តក្រចេះ នៅក្នុងអំឡុងសកម្មភាពចុះល្បាតរបស់ពួកគេ។ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣

## ការឃ្លាំមើលសកម្មភាពល្មើសច្បាប់ផ្សេងៗ របស់សហគមន៍

សកម្មភាពឃ្លាំមើលដែលធ្វើឡើងដោយសហគមន៍រួមមាន បណ្តាញសហគមន៍ព្រៃឡង់ (PLCN) បណ្តាញសហគមន៍ព្រៃព្រះរកា (**PFCN**) និងបណ្តាញសង្ឃសហគមន៍រុក្ខាវ៉ន (MCF) កំណត់គោលដៅសំខាន់ៗមួយចំនួន ឆ្លើយតបនឹង GBF ដែលអនុម័តឡើងនៅ COP១៥។ តាមរយៈការចងក្រងឯកសារ និងការប្រយុទ្ធប្រឆាំងនឹងការកាប់ឈើខុសច្បាប់ និងបទល្មើសព្រៃឈើផ្សេងៗទៀត បណ្តាញសហគមន៍កំពុងគាំទ្រគោលដៅទី៥ ដែលមានគោលបំណងធានានូវនិរន្តរភាពក្នុងការប្រើប្រាស់ប្រភេទរុក្ខជាតិ។ព្រៃ។

ការកើនឡើងគួរឱ្យកត់សម្គាល់នូវសកម្មភាពឃ្លាំមើល ជាពិសេសពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់ ការការពារដើមឈើប្រណីត និងដើមច្បោះ ស្របតាមគោលដៅទី៣ ដើម្បីអភិរក្សយ៉ាងហោចណាស់ ៣០% នៃផ្ទៃដីរបស់ពិភពលោក។ លើសពីនេះទៀត ការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនេះ បង្ហាញពីសារៈសំខាន់នៃគោលដៅទី២២ និងគោលដៅទី២៣ ដែលបញ្ជាក់ពីការគោរពចំពោះចំណេះដឹង និងការអនុវត្តរបស់ជនជាតិដើមភាគតិច និងការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានក្នុងដំណើរការធ្វើការសម្រេចចិត្ត។

ទិន្នន័យដែលទាក់ទងនឹងអាកាសធាតុ និងអន្តរកម្មជាមួយអាជ្ញាធរ គាំទ្របន្ថែមទៀតដល់គោលដៅទី១១ ដែលផ្តោតលើការរក្សា និងបង្កើនភាពភាពល្អឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធអេកូឡូស៊ីដែលរួមចំណែកដោយផ្ទាល់ និងដោយប្រយោលផ្តល់សម្រាប់សុខុមាលភាព និងគុណភាពជីវិត។ ទោះបីជាប្រឈមមុខនឹងការបៀតបៀន និងការវិតត្បិតក៏ដោយ ក៏ ការលះបង់របស់សមាជិកសហគមន៍បង្ហាញពីតួនាទីសំខាន់ដែលសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដើរតួក្នុងការសម្រេចបាននូវគោលដៅអភិរក្សជីវចម្រុះជាសកល។

**ទោះជាយ៉ាងនេះក៏ដោយ សកម្មភាពកាប់ឈើខុសច្បាប់ដែលត្រូវបានរកឃើញនៅក្នុងដែនជម្រកសត្វព្រៃ បង្ហាញពីការបំពានយ៉ាងធ្ងន់ធ្ងរលើគោលដៅ COP១៥។ ការកាប់ដើមឈើរាប់រយដើម និងការកាប់រានព្រៃក្រាស់ ធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងដើម្បីអភិរក្ស ៣០% នៃផ្ទៃដីរបស់ពិភពលោក (គោលដៅទី៣) និងធានាឱ្យមាននិរន្តរភាពនៃការប្រើប្រាស់ប្រភេទរុក្ខជាតិព្រៃ (គោលដៅទី៥) ។ សកម្មភាពទាំងនេះធ្វើឱ្យផលប៉ះពាល់បម្រែបម្រួលអាកាសធាតុកាន់តែធ្ងន់ធ្ងរផងដែរ (គោលដៅទី៨) និងផ្ទុយពីគោលដៅគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព (គោលដៅទី១០)។**

លើសពីនេះទៅទៀត ការបដិសេធរបស់អាជ្ញាធរចំពោះភាពធ្ងន់ធ្ងរនៃបញ្ហាទាំងនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងកិច្ចខិតខំប្រឹងប្រែងអភិរក្ស (**គោលដៅទី២២ និងទី២៣**) ដែលជាអ្នកថែរក្សាដីសំខាន់ នៅតំបន់ជីវចម្រុះទាំងអស់នេះ។

ជាងនេះទៅទៀត ការសាងសង់ផ្លូវថ្មីដោយក្រុមហ៊ុន ស៊ីងបាយអូថេក (Think Biotech) កំពុងជួយសម្រួលដល់ការកាប់ឈើខុសច្បាប់នៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ ដែលបង្កការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ជីវចម្រុះ និងសហគមន៍ជនជាតិដើមភាគតិច។ ផ្លូវទាំងនេះរារាំងកិច្ចខិតខំប្រឹងប្រែងស្តារប្រព័ន្ធអេកូឡូស៊ី (**គោលដៅទី២**) និងកាត់បន្ថយផ្ទៃដីតំបន់ការពារ (**គោលដៅទី៣**)។ ការកាប់ឈើ និងការជួញដូរខុសច្បាប់ រំលោភលើនិរន្តរភាព និងការប្រើប្រាស់រុក្ខជាតិព្រៃស្របច្បាប់ (**គោលដៅទី៥**) និងរួមចំណែកដល់ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (**គោលដៅទី៨**) ។ លើសពីនេះ ការរំខាន ដល់ប្រព័ន្ធអេកូឡូស៊ី និងការបាត់បង់ផលពីជីវចម្រុះដែលសម្រួលដល់ភាពធន់របស់ប្រព័ន្ធអេកូឡូស៊ី (**គោលដៅទី១១**)។ សកម្មភាពនេះក៏ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងទឹកដីប្រពៃណីរបស់ជនជាតិដើមភាគតិច (**គោលដៅទី២២ និងទី២៣**) ដែលពឹងផ្អែកលើព្រៃឈើទាំងនេះសម្រាប់ការចិញ្ចឹមជីវិត និងការប្រតិបត្តិវប្បធម៌របស់ពួកគេផងដែរ។



↑ រូបភាពទី៥៧

សហគមន៍ខេត្តព្រះវិហារ ចុះឃ្លាំមើលសកម្មភាពកាប់ឈើខុសច្បាប់។ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣

ប្រតិបត្តិការរុករករ៉ែមាសនៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ បង្ហាញពីបញ្ហាប្រឈមជាច្រើនដល់ការអភិរក្សជីវចម្រុះ និងសហគមន៍ជនជាតិដើមភាគតិច។ ការកាប់រានដីព្រៃរាប់រយហិចតា សម្រាប់ការជីកយករ៉ែរារាំងដល់ការស្តារប្រព័ន្ធអេកូឡូស៊ី (**គោលដៅទី២**) និងធ្វើឱ្យខូចដល់ការអភិរក្សតំបន់ការពារ (**គោលដៅទី៣**)។ ការប្រើប្រាស់សារធាតុគ្រោះថ្នាក់ផ្សេងៗដូចជាស៊ីយ៉ាញ៉ូរ (Cyanide) បង្កហានិភ័យយ៉ាងខ្លាំងចំពោះជីវចម្រុះ (**គោលដៅទី៦**) និងធ្វើឱ្យប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុកាន់តែធ្ងន់ធ្ងរ (**គោលដៅទី៨**)។ សកម្មភាពទាំងនេះបានគំរាមកំហែងដល់ប្រភេទរុក្ខជាតិដែលជិតផុតពូជ និងរំខានដល់ប្រព័ន្ធអេកូដែលរួមចំណែកដោយផ្ទាល់ និងដោយប្រយោលផ្តល់សម្រាប់សុខុមាលភាព និងគុណភាពនៃជីវិត។ ធ្វើឱ្យប៉ះពាល់ដល់ការល្អដូចដើមឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី (**គោលដៅទី១១**)។ លើសពីនេះ កង្វះការវាយតម្លៃផលប៉ះពាល់បរិស្ថានជាសាធារណៈ និងការបំពានផ្លូវច្បាប់ដែលអាចប៉ះពាល់ដល់ការគោរពចំពោះចំណេះដឹង និងប្រតិបត្តិរបស់ជនជាតិដើមភាគតិច (**គោលដៅទី១៤**)។ ការពង្រីកប្រតិបត្តិការរុករករ៉ែក៏រំលោភលើសិទ្ធិ និងទឹកដីរបស់សហគមន៍ជនជាតិដើមភាគតិចផងដែរ (**គោលដៅទី២២ និងទី២៣**) ដែលជាដៃគូដ៏សំខាន់ក្នុងការអភិរក្សជីវចម្រុះ។

# ការឃ្លាំមើលជីវចម្រុះ

ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃរុក្ខជាតិសម្រាប់សិប្បកម្ម **អនុផលដែលអាចបរិភោគបាន និងឱសថ** នៅក្នុងដែនជម្រកសត្វព្រៃរបស់កម្ពុជា ស្របតាមគោលដៅសំខាន់ៗមួយចំនួនរបស់ GBF។ ដោយធានាថាការប្រើប្រាស់ ការប្រមូលផល និងការជួញដូរប្រភេទរុក្ខជាតិព្រៃទាំងនេះមាននិរន្តរភាព និងស្របច្បាប់ (**គោលដៅទី៥**)។ សហគមន៍មូលដ្ឋានអាចទទួលបានអត្ថប្រយោជន៍ពីការបែងចែកដោយសមធម៌នូវធនធានដីមានសក្តានុពលផ្សេងៗ (**គោលដៅទី៩**)។ លើសពីនេះទៀត ការលើកកម្ពស់ការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព (**គោលដៅទី១០**) គាំទ្រដល់គោលដៅទូលំទូលាយនៃការគ្រប់គ្រងតំបន់កសិកម្ម និងព្រៃឈើប្រកបដោយនិរន្តរភាព រួមចំណែកដល់ការអភិរក្សជីវចម្រុះ និងសុខុមាលភាពសហគមន៍។



↑ **រូបភាពទី៥៨**
សហគមន៍ខេត្តក្រចេះ ប្រមូលផលផ្សិត



↑ **រូបភាពទី៥៩**
ដើមឈើមួយដើមដួលរលំដោយសារព្យុះភ្លៀង។ ព្រឹត្តិការណ៍អាកាសធាតុខ្លាំងខ្លាបែបនេះបានកើតមានច្រើនជាងពេលណាៗទាំងអស់។ ត្រូវបានកត់ត្រានៅក្នុងដែនជម្រកសត្វព្រៃព្រះរកា នៅថ្ងៃទី៣ ខែមីថុនា ឆ្នាំ២០២៣

## ការការពារ និងការស្តារឡើងវិញនូវទីតាំងសម្រាប់ដើមឈើប្រណីត បានកំណត់គោលដៅជាច្រើននៅក្នុងកិច្ចព្រមព្រៀង COP១៥ ។

កិច្ចខិតខំប្រឹងប្រែងដើម្បីស្តារប្រព័ន្ធអេកូឡូស៊ីដែលខូចខាត (**គោលដៅទី២**) និងអភិរក្សតំបន់ដីសំខាន់ៗ (**គោលដៅទី៣**) គឺមានសារៈសំខាន់សម្រាប់ការថែរក្សាប្រភេទរុក្ខជាតិដែលមានតម្លៃ និងភាគច្រើនជិតផុតពូជទាំងនេះ។ លើសពីនេះការអនុវត្តការគ្រប់គ្រងប្រកបដោយនិរន្តរភាព ជួយកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (**គោលដៅទី៨**) ដោយការថែរក្សាគម្របព្រៃឈើ និងបង្កើនការប្រមូលផ្តុំកាបូន ដោយទទួលបានការគាំទ្រទាំងគោលបំណងបរិស្ថាន និងសេដ្ឋកិច្ច។

កិច្ចខិតខំប្រឹងប្រែងអភិរក្សដែលមានគោលបំណងការពារប្រភេទសត្វត្រូវបានភ្ជាប់ដោយផ្ទាល់ទៅនឹងគោលដៅជាច្រើននៃ COP១៥។ ការកាត់បន្ថយអត្រា ប្រភេទសត្វជិតផុតពូជ (**គោលដៅទី៤**) និងការកាត់បន្ថយផលប៉ះពាល់ ដោយប្រភេទសត្វរាតត្បាត (**គោលដៅទី៦**) គឺចាំបាច់សម្រាប់ការថែរក្សាជីវចម្រុះ។ លើសពីនេះ ការការពារប្រភេទសត្វ ធ្វើឱ្យប្រសើរដូចដើមឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធអេកូឡូស៊ីសំខាន់ៗដែលរួមចំណែកដោយផ្ទាល់ និងដោយប្រយោល ផ្តល់សម្រាប់សុខុមាលភាព និងគុណភាពជីវិត (**គោលដៅទី១១**) ដូចជាការបំពុល និងការនាំយកគ្រាប់ពូជទៅទីកន្លែងថ្មី ដែលមានសារៈសំខាន់សម្រាប់សុខភាព ទាំងប្រព័ន្ធធម្មជាតិ និងមនុស្ស។

# ផែនការសម្រាប់អនាគត



←រូបភាពទី៦០ សហគមន៍នៅដែនជម្រកសត្វព្រៃព្រះរការក្សាទុកកូនឈើប្រភេទជិតផុតពូជពីតំបន់ងាយរងគ្រោះដើម្បីដាំវាឡើងវិញ។

កំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលកម្ពុជាក្នុងការឆ្លើយតបទៅនឹងគោលដៅ COP១៥ ដែលផ្តោតលើគោលបំណងសំខាន់ៗមួយចំនួនដែលបានគូសបញ្ជាក់នៅក្នុង Kunming-Montreal GBF។ ជាពិសេស ប្រទេសកម្ពុជាមានគោលបំណងសម្រេចឱ្យបាននូវ

**គោលដៅទី៣ ដែលកំណត់ថា យ៉ាងហោចណាស់ ៣០% នៃផ្ទៃទឹក និងដីគោក ត្រូវបានអភិរក្ស និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៅឆ្នាំ២០៣០។**




នេះស្របទៅនឹងការពង្រីកតំបន់ការពារនាពេលថ្មីៗនេះ និងការបង្កើតយុទ្ធសាស្រ្តចក្រាវិស័យបរិស្ថាន (CES) ២០២៣-២០២៨ ដែលសង្កត់ធ្ងន់លើការគ្រប់គ្រងប្រកបដោយចីរភាព និងការចូលរួមរបស់សហគមន៍ក្នុងកិច្ចខិតខំប្រឹងប្រែងអភិរក្ស។ លើសពីនេះទៅទៀត រដ្ឋាភិបាលកំពុងដោះស្រាយគោលដៅទី២ ដែលអំពាវនាវឱ្យមានការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលខូចខាតឱ្យបានយ៉ាងហោចណាស់ ៣០% នៅឆ្នាំ២០៣០។ នេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការបង្កើនការគម្របព្រៃឈើដល់ ៦០% នៅឆ្នាំ២០៥០ តាមរយៈការស្តារព្រៃឈើឡើងវិញ និងការអនុវត្តប្រកបដោយនិរន្តរភាព។

ទោះជាយ៉ាងណាក៏ដោយ វិធានការជាវិជ្ជមានទាំងនេះត្រូវបានប្រឈមទៅនឹងការព្រួយបារម្ភទាក់ទងនឹងប្រសិទ្ធភាពក្នុងការអនុវត្ត និងគ្រប់គ្រងតំបន់ដែលទើបបានកំណត់ថ្មីៗ ជាពិសេសចំពោះបញ្ហានៃការកាប់ឈើខុសច្បាប់ និងការកេងប្រវ័ញ្ចធនធានដែលកំពុងបន្ត។ ភាពផ្ទុយគ្នានេះ បានបង្ហាញពីបញ្ហាប្រឈមនៃការប្រែក្លាយគោលដៅប្រកបដោយមហិច្ឆតាទៅជាលទ្ធផលជាក់ស្តែង ដូច្នេះផែនការរបស់រដ្ឋាភិបាលនឹងត្រូវការជំនះឧបសគ្គក្នុងការអនុវត្តសំខាន់ៗ ដើម្បីធានាបាននូវវឌ្ឍនភាពពិតប្រាកដក្នុងការអភិរក្សជីវចម្រុះ និងការស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ។

ការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានក្នុងការអភិរក្សជីវចម្រុះ គឺជាមូលដ្ឋានគ្រឹះនៃក្របខ័ណ្ឌជីវចម្រុះសកល Kunming-Montreal។ ការគោរព ការប្រើប្រាស់ចំណេះដឹង និងការអនុវត្តរបស់សហគមន៍ទាំងនេះ (**គោលដៅទី២២**) ធានាថា កិច្ចខិតខំប្រឹងប្រែងអភិរក្សមានលក្ខណៈសមស្រប និងមានប្រសិទ្ធភាព។ ជាងនេះទៅទៀត ការលើកកម្ពស់ការចូលរួមរបស់ពួកគេនៅក្នុងដំណើរការការធ្វើសេចក្តីសម្រេចចិត្ត (**គោលដៅទី២៣**) ជំរុញយុទ្ធសាស្រ្តអភិរក្សប្រកបដោយសមធម៌ និងការសន្ទនា ដោយទទួលស្គាល់តួនាទីដែលមិនអាចខ្វះបានដែលជនជាតិដើមភាគតិចដើរតួក្នុងការការពារជីវចម្រុះ។.

**នៅក្នុងសេចក្តីសន្និដ្ឋាន កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ជាច្រើនដូចជា បណ្តាញសហគមន៍ព្រៃឡង់ បណ្តាញសហគមន៍ព្រៃព្រះរកា និងសង្ឃសហគមន៍រុក្ខាវ័ន ជាឧទាហរណ៍អំពីតួនាទីដ៏សំខាន់ដែលសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដើរតួក្នុងការសម្រេចបាននូវគោលដៅអភិរក្សជីវចម្រុះសកល។**

ការលះបង់របស់ពួកគេក្នុងការកិច្ចការឃ្លាំមើល និងការប្រយុទ្ធប្រឆាំងនឹងសកម្មភាពខុសច្បាប់ បើទោះជាមានការប្រឈមមុខនឹងបញ្ហាសំខាន់ៗក៏ដោយ វាបានបញ្ជាក់ពីសារៈសំខាន់ នៃការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងបរិស្ថាន។ រួបរួមគ្នា យើងអាចធ្វើការឆ្ពោះទៅអនាគតមួយ ដែលជីវចម្រុះត្រូវបានអភិរក្ស ប្រព័ន្ធអេកូឡូស៊ីមានភាពល្អដូចដើមឡើងវិញ និងសុខុមាលភាពរបស់សហគមន៍ទាំងអស់ត្រូវបានការពារ។

# » សេចក្តីថ្លែងការណ៍ពីសហគមន៍

## ស្តីអំពី

### សកម្មភាពបទល្មើសខុសច្បាប់ ព្រៃឈើ ការកាប់រានដីព្រៃ ការចាប់សត្វព្រៃ ការប្រើប្រាស់អាវុធកែច្នៃ អាជីវកម្មរ៉ែ ក្នុងតំបន់ព្រៃឡង់នៅតែបន្តកើតឡើង

យើងខ្ញុំទាំងអស់គ្នាជាសមាជិកបណ្តាញសហគមន៍ព្រៃឡង់ទាំងបួនខេត្តរួមមាន៖ កំពង់ធំ ព្រះវិហារ ក្រចេះ និង ស្ទឹងត្រែង ដែលកំពុងធ្វើការស្មគ្រ័ចិត្តការពារព្រៃ ការពារដែនជម្រកសត្វព្រៃ ព្រៃឡង់ អស់រយៈពេលជាង ២០ឆ្នាំមកហើយបាននឹងកំពុងបន្តឃ្លាំមើល យ៉ាងយកចិត្តទុកដាក់ទៅលើ សកម្មភាពកាប់ឈើ ការដឹកជញ្ជូនឈើ ការប្រើប្រាស់អាវុធកែច្នៃ និងការឆក់សត្វព្រៃអនាធិបតេយ្យ។ បើទោះជាបណ្តាញត្រូវបានហាមឃាត់មិនឲ្យចុះល្បាតក្នុងតំបន់ការពារព្រៃឡង់ ចាប់តាំងពីថ្ងៃទី ខែកុម្ភៈ ដើមឆ្នាំ២០២០ ដោយក្រសួងបរិស្ថានក៏ដោយ។

នៅពេលដែលព្រៃឡង់ ត្រូវបានដាក់ជាដែនជម្រកសត្វព្រៃ ព្រៃឡង់ (តំបន់ការពារ) យើងខ្ញុំសង្កេតឃើញថា បទល្មើសមានការកើនឡើងច្រើន ហើយអ្វីដែលគួរឲ្យកត់សម្គាល់ជាងនេះទៅទៀតនោះគឺ តាំងពីមន្ត្រីឧទ្យានុរក្សក្រសួងបរិស្ថាន បានហាមឃាត់បណ្តាញសហគមន៍ព្រៃឡង់មិនឲ្យចុះល្បាត ទប់ស្កាត់បទល្មើស ដូច្នេះ ជនល្មើសមានសេរីភាពចេញចូលព្រៃឡង់ដើម្បីកាប់ឈើ កាប់រានដីព្រៃ និងដឹកជញ្ជូនឈើយ៉ាងរលូន ដោយគ្រាន់តែបង់ប្រាក់ជូនមន្ត្រីតាមស្នាក់ការត្រួតពិនិត្យ ជាថ្នូរនឹងការទទួលបានការអនុញ្ញាតិឲ្យប្រព្រឹត្តបទល្មើសក្នុងព្រៃឡង់។




**ចាប់តាំងពីដើមឆ្នាំ២០២៣មក យើងខ្ញុំទាំងអស់គ្នាបានសង្កេតឃើញ សកម្មភាពល្មើសច្បាប់ នៅជុំវិញ និង ក្នុងតំបន់ព្រៃឡង់ បន្តកើតមានយ៉ាងអនាធិបតេយ្យដូចជា៖**

**អាជីវកម្មរ៉ែ**

» អាជីវកម្មរ៉ែក្នុងតំបន់ព្រៃឡង់ ដូចជាក្រុមហ៊ុន ឡេត ចេង ម៉ាញនីង ឌីវេឡុបម៉ិន ឯ.ក មានថៅកែជាជនជាតិចិន និងក្រុមមិនមានអាជ្ញាប័ណ្ណអាជីវកម្មរ៉ែ នៅតំបន់ភ្នំជី ក្នុងភូមិសាស្ត្រព្រំប្រទល់ខេត្តក្រចេះ និងខេត្តកំពង់ធំ ។

**ការកាប់បំផ្លាញដើមឈើធំៗ**

» ការកាប់បំផ្លាញដើមឈើធំៗ សកម្មភាពការដឹកជញ្ជូនឈើជាច្រើនតាមគោយន្តកន្ត្រៃក្នុងមួយថ្ងៃៗ និងឧបករណ៍សម្រួលដល់ការកាប់ឈើដឹកចូលទៅក្រុមហ៊ុន ដោយពុំមាននូវចំណាត់ការច្បាស់លាស់ពីអាជ្ញាធរពាក់ព័ន្ធ។

**ការកាប់រានដីព្រៃ និងការតាំងទីលំនៅអនាធិបតេយ្យ**

» ការកាប់រានដីព្រៃ និងការតាំងទីលំនៅអនាធិបតេយ្យនៅក្នុងតំបន់ទ្រនាប់នៃព្រៃការពារដែនជម្រកសត្វព្រៃ ព្រៃឡង់ ដោយមានអ្នកមានអំណាចមួយចំនួននៅពីក្រោយ និងប្រជាពលរដ្ឋអ្នកចំណូលស្រុកថ្មី។

**ការប្រើប្រាស់គ្រឿងញៀន ការផលិតនិងប្រើប្រាស់អាវុធកែច្នៃ**

» ការប្រើប្រាស់គ្រឿងញៀន ការផលិតនិងប្រើប្រាស់អាវុធកែច្នៃ យ៉ាងអនាធិបតេយ្យពីសំណាក់ក្រុមបទល្មើស និងប្រជាពលរដ្ឋរស់នៅក្បែរតំបន់ព្រៃឡង់ បានគំរាមកំហែងដល់អ្នកការពារធនធានធម្មជាតិ និងសត្វព្រៃ។

**ការឆក់ ដាក់មងយកសត្វ**

» ការឆក់ ដាក់មងយកសត្វ និងការប្រើប្រាស់ឧបករណ៍ខុសច្បាប់ផ្សេងទៀត បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់សត្វព្រៃ និរន្តភាពជីវចម្រុះ និងបរិស្ថាន។

## សកម្មភាពល្មើសច្បាប់អនាធិបតេយ្យទាំងនេះ ធ្វើឲ្យពួកយើងមានសេចក្តីកង្វល់ជាខ្លាំង។ យើងខ្ញុំទាំងអស់គ្នា សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ មេត្តា៖

» ស្នើសុំរាជរដ្ឋាភិបាលតាមដានត្រួតពិនិត្យ និងដកហូតសិទ្ធិសម្បទានសេដ្ឋកិច្ចក្រុមហ៊ុនណាដែលមិនបានអនុវត្តន៍តាមកិច្ចព្រមព្រៀងផ្សេងៗ ក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់។
» ត្រួតពិនិត្យ និងវាយតម្លៃតួនាទីជាមន្ត្រីរាជការរូបណា ដែលពាក់ព័ន្ធជាមួយបទល្មើស និងអសកម្មក្នុងការបំពេញតួនាទីរបស់ខ្លួន។
» ស្នើសុំរាជរដ្ឋាភិបាល ពិសេសក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ ចុះត្រួតពិនិត្យ និងរៀបចំផែនការយុទ្ធសាស្ត្រជាក់លាក់ដើម្បីប្រយុទ្ធប្រឆាំងការកាប់បំផ្លាញព្រៃឈើ ការកាប់រានដីព្រៃសម្រាប់កសិកម្មថ្មីៗ ការតាំងទីលំនៅអនាធិបតេយ្យ កាំភ្លើងកែច្នៃ ការឆក់សត្វ និងសម្ភារៈបម្រើឲ្យការប្រព្រឹត្តបទល្មើសផ្សេងៗទៀត។
» រាជរដ្ឋាភិបាលត្រូវតែអនុវត្តន៍បទបញ្ញាត្តិ និងច្បាប់នានាក្នុងកិច្ចការការពារព្រៃឈើក្នុងតំបន់អភិរក្ស។
» អំពាវនាវ និងលើកទឹកចិត្តដល់ប្រជាជនកម្ពុជា និងសាកលលោកទាំងមូល ត្រូវចូលរួមយ៉ាងសកម្មទាំងអស់គ្នាដោយផ្ទាល់ ឬប្រយោលដើម្បីបុព្វហេតុការពារធនធានធម្មជាតិ។
» សូមភាគីពាក់ពន្ធ័បញ្ឈប់ការទទួលទិញឈើខុសច្បាប់គ្រប់ប្រភេទ ដែលមានប្រភពពីប្រទេសកម្ពុជា។
» សូមឲ្យតួអង្គអន្តរជាតិសំខាន់ៗ ធ្វើការចាប់អារម្មណ៍ និងវិភាជន៍នូវធនធានដល់កម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតំណាងសហគមន៍តាមរយៈ លេខទូរស័ព្ទដូចខាងក្រោម៖

» លោក ហឿន សុភាព ០៩៦ ៦៣២ ៨៥៧៣
» លោក ម៉ិញ នី ០៩៦ ៣០០ ២៧៦២
» លោក ស្រី ថី ០១៤ ៣៧១ ៩២៦
» លោក យុត សឿម ០១៧ ៦៤០ ០៨៤
» លោក ស្វាយ សុង ០៧១ ៤៥១ ៩៤៦៥
» លោក ឯក សុវណ្ណា ០៩៧ ៦៤៤ ៩៩៩៨
» លោក ពេជ្រ សារិក ០៩៧ ៩២៣ ៣១ ៩៩
» លោក ខេង ខូ ០៩៥ ២២៤ ៩៣៣

**“យើងរួមគ្នាការពារព្រៃឡង់! ព្រៃឡង់ ជាព្រៃរបស់យើងទាំងអស់គ្នា!”**

**ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤**

**រូបភាពគម្របខាងមុខ**

សហគមន៍ខេត្តស្ទឹងត្រែង រាយការណ៍ពីការឈូសឆាយមួយកន្លែងនៅក្នុងសម្បទានមួយ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៣។

**រូបភាពផ្ទៃខាងក្រោយ**
សហគមន៍ខេត្តព្រះវិហារនៅអំឡុងការចុះល្បាតមួយ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣។



ការបោះពុម្ពផ្សាយនេះ ត្រូវបានផលិតឡើងដោយមានការគាំទ្រ ផ្នែកហិរញ្ញវត្ថុពី សហភាពអឺរ៉ុប (European Union)។ ខ្លឹមសាររបស់ របាយការណ៍នេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ CEEJA ដោយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ សហភាពអឺរ៉ុបនោះឡើយ។

ព័ត៌មានដែលមាននៅក្នុងឯកសារនេះ គឺជាកម្មសិទ្ធិបញ្ញារបស់ CEEJA។ សូមស្វាគមន៍ចំពោះការប្រើប្រាស់ បោះពុម្ពផ្សាយ និងការចែកចាយ ឯកសារនេះឡើងវិញ ដោយត្រូវផ្តល់នូវប្រភពឯកសារយោង។

CEEJA សូមថ្លែងអំណរគុណចំពោះ មជ្ឈមណ្ឌលស្រាវជ្រាវរួម (JRC) របស់គណៈកម្មការអឺរ៉ុប ដែលបានផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេស ដើម្បីឃ្លាំមើលការរំខានគម្រប់ព្រៃឈើ ដោយប្រើប្រាស់ឧបករណ៍ FCDM អ្នកហាត់ការមកពីសាកលវិទ្យាល័យ Copenhagen និងអ្នករួមការងារទាំងអស់ដែលបានផ្តល់ជំនួយរបស់ពួកគេ ដោយស្ម័គ្រចិត្ត។ របាយការណ៍នេះ មិនអាចធ្វើឡើងបានឡើយ បើគ្មានការរួមចំណែករបស់ពួកគេ។

កម្មវិធីអែពព្រៃឡង់ត្រូវបានបង្កើតឡើងដោយផ្អែកលើ Sapelli៖ កម្មវិធី open-source ដែលសម្រួលដល់ការប្រមូលទិន្នន័យអន្តរភាសា ឬឧបសគ្គអក្ខរកម្ម ដោយកំណត់រូបភាពបង្ហាញផ្លូវសម្រាប់អ្នកប្រើប្រាស់។ សម្រាប់ព័ត៌មានបន្ថែម៖ http://www.sapelli.org/

ផែនទីទាំងអស់ត្រូវបានបង្កើតឡើងដោយប្រើកម្មវិធី ArcGIS Pro 2.7.1។ រូបភាពទី១៦ ទី២០ ទី២១ និងទី២២ គឺជាកម្មសិទ្ធិបញ្ញារបស់អ្នកស្រី Nerea Turreira Garcia និងលោក Dimitris Argyriou។ រូបភាពទី១៥ និងទី១៦ គឺជាកម្មសិទ្ធិបញ្ញារបស់ Colline Bonnet។ រូបភាពផ្សេងៗទៀត គឺជាកម្មសិទ្ធិបញ្ញារបស់សហគមន៍ដែលបានប្រមូល ហើយរូបភាពទាំងអស់នេះត្រូវបានការពារក្រោមអាជ្ញាប័ណ្ណ Creative Commons (CC BY-NC-ND 4.0)។ រចនាក្រាហ្វិច និងតារាងទិន្នន័យព័ត៌មានដោយ Carolina Salassa (carolina.salassa@outlook.it)។

**កំណែលើកទី១ ខែកញ្ញា ឆ្នាំ២០២៤។**